ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល

# ២០២៣-២០២៥

# របស់និយ័តករធានារ៉ាប់រងកម្ពុជា

រៀបចំដោយ

**និយ័តករធានារ៉ាប់រងកម្ពុជា**

**នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

២០២៣

# មាតិកា


អារម្ភកថា ........ iii

ផ្នែកទី១៖ សេចក្តីផ្តើម ........ ១

ផ្នែកទី២៖ និយ័តករធានារ៉ាប់រងកម្ពុជា ........ ៣

២.១. រចនាសម្ព័ន្ធ ........ ៣

២.២. ធនធានមនុស្ស ........ ៤

ផ្នែកទី៣៖ ចក្ខុវិស័យ គោលបំណង និងគោលដៅ ........ ៤

ផ្នែកទី៤៖ គុណតម្លៃស្ថាប័ន ........ ៥

ផ្នែកទី៥៖ សមិទ្ធផលនិងបញ្ហាប្រឈមក្នុងឆ្នាំ២០២២ ........ ៦

៥.១. ក្របខណ្ឌស្ថាប័ន ........ ៧

៥.២. ក្របខណ្ឌបច្ចេកទេស ........ ៧

៥.៣. ក្របខណ្ឌបញ្ញត្តិកម្ម ........ ៩

៥.៤. សូចនាករគន្លឹះ ........ ៩

៥.៥. បញ្ហាប្រឈម ........ ៩

ផ្នែកទី៦៖ ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥ ........ ១០

៦.១. និន្នាការសកលនៃវិស័យធានារ៉ាប់រង ........ ១០

៦.២. ក្របខណ្ឌស្ថាប័ន ........ ១២

៦.១.១. សមត្ថភាពស្ថាប័ន ........ ១២

៦.១.២. ការតភ្ជាប់ ........ ១៤

៦.១.៣. កិច្ចសហប្រតិបត្តិការ ..................... ១៥

៦.២. ក្របខណ្ឌបច្ចេកទេស ..................... ១៦

៦.២.១. ការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ ..................... ១៦

៦.២.២. ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ ..................... ១៧

៦.២.៣. កិច្ចការពារអតិថិជន ..................... ១៨

៦.២.៤. ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ..................... ១៨

៦.២.៥. ការផ្សព្វផ្សាយ និងការអប់រំសាធារណជន ..................... ១៩

៦.២.៦. ការធានារ៉ាប់រងជាភាគពួកិច្ច ..................... ១៩

៦.៣. ក្របខណ្ឌបញ្ញត្តិកម្ម ..................... ២០

ផ្នែកទី៧÷ យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ ..................... ២១

៧.១. ស្ថាប័នទទួលបន្ទុក ..................... ២១

៧.២. ការត្រួតពិនិត្យ និងការវាយតម្លៃ ..................... ២២

ផ្នែកទី៨÷ សេចក្តីសន្និដ្ឋាន ..................... ២៣

ផ្នែកទី៩ ÷ តារាងឧបសម្ព័ន្ធ ..................... ២៤

ឧបសម្ព័ន្ធ១. សមិទ្ធផលសកម្មភាពការងាររបស់ន.ធ.ក.ឆ្នាំ២០២២ ..................... ២៤

ឧបសម្ព័ន្ធ២. ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥ ..................... ៣៥

ឧបសម្ព័ន្ធ៣. ផែនការសកម្មភាពលម្អិតប្រចាំឆ្នាំ២០២៣ ..................... ៤៩

## អារម្ភកថា

ក្នុងឆ្នាំ២០២២ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** សម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចជាតិក្នុងរង្វង់ប្រមាណ ៥,២% ដែលជាអត្រាកំណើនសេដ្ឋកិច្ចមួយរឹងមាំ ទោះបីជាត្រូវបានបន្ទប់បង្អាក់ដោយបញ្ហាប្រឈមសកលមួយចំនួនក៏ដោយ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភាក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានកំណត់ទិសដៅ ដើម្បីកំណើនការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សម្រាប់កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០ នឹងបន្តរក្សាបាននូវនិន្នាការកំណើនសេដ្ឋកិច្ចវិជ្ជមានគួរឱ្យកត់សម្គាល់ក្នុងរង្វង់ប្រមាណ ៥,៦% ក្នុងឆ្នាំ២០២៣។

ផ្អែកលើគោលនយោបាយកំណែទម្រង់ជារចនាសម្ព័ន្ធសំខាន់ៗមួយចំនួនរបស់រាជរដ្ឋាភិបាល ក្នុងនោះមានដូចជា “**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤**”, “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣**”, និង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥**”, ការធ្វើពិពិធកម្មផលិតផលហិរញ្ញវត្ថុនៅក្នុងវិស័យហិរញ្ញវត្ថុ និងការជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ គឺជាអាទិភាពសំខាន់មួយក្នុងចំណោមអាទិភាពសំខាន់ៗដទៃទៀត ដើម្បីជំរុញការកសាងភាពធន់នៃសេដ្ឋកិច្ច និងសង្គមឱ្យកាន់តែរឹងមាំនិងមានភាពឆ្លើយតបខ្ពស់ និងបង្កើតបានជាចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចថ្មី និងឱ្យកាន់តែរឹងមាំបន្ថែមទៀត។ ការពង្រឹងប្រព័ន្ធធនាគារ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ គឺជាគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបន្តអភិវឌ្ឍក្របខណ្ឌគតិយុត្ត ជំរុញភាពស៊ីជម្រៅហិរញ្ញវត្ថុ ពង្រឹងសមត្ថភាពស្ថាប័ន និងអក្ខរកម្មហិរញ្ញវត្ថុ និងលើកស្ទួយឌីជីថលូបនីយកម្មក្នុងវិស័យហិរញ្ញវត្ថុ។ ទន្ទឹមនឹងនេះ “**ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០**” ដែលបានដាក់ចេញឱ្យប្រើប្រាស់ក្នុងឆ្នាំ២០២៣ បានក្លាយជាបង្គោលចរមួយ សម្រាប់និយ័តករនិងអង្គភាពក្រោមឱវាទ នៃអាជ្ញាធរសេវាហិរញ្ញ-

វត្ថុមិនមែនធនាគារទាំងអស់ ធ្វើការបន្សុីគ្នា ជាពិសេសលើចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃស្ថាប័ន ដោយផ្អែកលើក្របខណ្ឌឆ្នាំ២០៣០ សម្រាប់យកធ្វើជាមូលដ្ឋានក្នុងការរៀបចំទិសដៅការងាររយៈពេលវែង។

វិស័យធានារ៉ាប់រង ដែលជាវិស័យមួយក្នុងចំណោមវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដើរតួនាទីជាយន្តការដ៏មានប្រសិទ្ធភាពមួយ ក្នុងការរួមចំណែកឆ្លើយតបទៅនឹងវិបត្តិ។ វិស័យធានារ៉ាប់រងបានរួមចំណែកយ៉ាងសំខាន់ ក្នុងការកាត់បន្ថយបន្ទុកហិរញ្ញវត្ថុ និងបង្កើតបានជាសំណាញ់សុវត្ថិភាពការពារមិនឱ្យប្រជាពលរដ្ឋធ្លាក់ចុះក្រោមបន្ទាត់ភាពក្រីក្រ ក្នុងពេលមានហានិភ័យកើតឡើងជាយថាហេតុ។ លើសពីនេះ វិស័យធានារ៉ាប់រងក៏រួមចំណែកគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ តាមរយៈការប្រែក្លាយបុព្វលាភធានារ៉ាប់រងឱ្យទៅជាប្រភពមូលធនសាច់ប្រាក់សម្រាប់ការវិនិយោគ ការបង្កើតឱកាសការងារក្នុងទីផ្សារ និងការលើកកម្ពស់ជីវភាពរស់នៅជូនប្រជាពលរដ្ឋ។ បុព្វលាភធានារ៉ាប់រងដុលរបស់កម្ពុជាមានចំនួនប្រមាណ ៣៣២ លានដុល្លារអាម៉េរិក ពោលគឺមានកំណើនប្រមាណ ១០% ក្នុងឆ្នាំ២០២២ និងបន្តមាននិន្នាការកើនឡើងជាលំដាប់ ដែលការណ៍នេះបានបង្ហាញឱ្យឃើញនូវសក្តានុពល នៃមូលធនសាច់ប្រាក់ពីវិស័យធានារ៉ាប់រងផងដែរ សម្រាប់ការវិនិយោគដែលគាំទ្រកំណើនសេដ្ឋកិច្ចជាតិ។ ទីផ្សារធានារ៉ាប់រងមានទ្រព្យសកម្មសរុបប្រមាណ ៩៧៨ លានដុល្លារអាម៉េរិក ខណៈដែលមូលនិធិភាគហ៊ុនិកសរុបមានប្រមាណ ៤០៨ លានដុល្លារអាម៉េរិក និងបានរួមចំណែកក្នុងសេដ្ឋកិច្ចក្នុងអត្រាប្រមាណ ១,១៧% ជាមួយនឹងដង់ស៊ីតេធានារ៉ាប់រងប្រមាណ ២០,៥៣ ដុល្លារអាម៉េរិកក្នុងមនុស្សម្នាក់។ ការរីកចម្រើននៃវិស័យធានារ៉ាប់រង បានបង្ហាញពីភាពធន់នៃទីផ្សារធានារ៉ាប់រងកម្ពុជា ក្នុងបរិបទនៃការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាក្រោយវិបត្តិជំងឺកូវីដ-១៩ និងបានបង្ហាញផងដែរពីការបន្តកើនឡើង នៃការរួមចំណែករបស់វិស័យធានារ៉ាប់រងនៅក្នុងសេដ្ឋកិច្ចជាតិ ដើម្បីរក្សាបាននូវស្ថិរភាពហិរញ្ញវត្ថុរឹងមាំ និងឈានឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុដែលមានពិពិធភាពរឹងមាំ ធន់នឹងវិបត្តិ និងប្រកបដោយបរិយាប័ន្ន។

ដើម្បីជំរុញការអភិវឌ្ឍនៃទីផ្សារធានារ៉ាប់រង ទាញយកកាលានុវត្តភាពថ្មីៗ និងដោះស្រាយបញ្ហាប្រឈម និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**) ជាតួអង្គសំខាន់មិនអាចខ្វះបាន ក្នុងការរៀបចំនិងអនុវត្តនូវ "**ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥ របស់ ន.ធ.ក.**" ដើម្បីកំណត់ឱ្យបាននូវសកម្មភាព

ការងារលម្អិត កែសម្រួលសកម្មភាពការងារតាមភាពជាក់ស្តែង និងតម្រង់ទិសដៅឱ្យស្របតាមការអភិវឌ្ឍនៃទីផ្សារធានារ៉ាប់រង និងបច្ចេកវិទ្យាថ្មីៗ។ ការណ៍នេះនឹងជួយជំរុញការអនុវត្តសកម្មភាពការងារប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព ជាពិសេសសម្រួលដល់យន្តការត្រួតពិនិត្យ និងវាយតម្លៃប្រចាំឆ្នាំ។ ទោះយ៉ាងណា ផ្អែកលើដំណើរវិវត្តយ៉ាងឆាប់រហ័សនៃទីផ្សារធានារ៉ាប់រង និងបច្ចេកវិទ្យាទំនើបៗ គួបផ្សំនឹងកត្តាជះឥទ្ធិពលខាងក្រៅ ខណៈដែលធនធាននៅមានកម្រិត **ន.ធ.ក.** ត្រូវប្រកាន់ខ្ជាប់នូវអភិក្រម "**រៀនផង ធ្វើផង**" ឬ "**ឆ្លងស្ទឹង ស្ទាបថ្ម**" ដើម្បីជម្នះនិងកែប្រែបញ្ហាប្រឈមឱ្យទៅជាការផ្តល់សម្ទុះនៃការអភិវឌ្ឍទីផ្សារធានារ៉ាប់រងឱ្យកាន់តែមានពិពិធភាពរឹងមាំ និងប្រកបដោយបរិយាប័ន្ន។

ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលរបស់ **ន.ធ.ក.** ២០២៣-២០២៥ គឺជាឯកសាររស់កំណែទី២ បន្ទាប់ពីបានអនុវត្តនូវផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលរបស់ **ន.ធ.ក.** ២០២២-២០២៤ ដោយបន្តផ្អែកលើក្របខណ្ឌសំខាន់ៗចំនួន៣ រួមមាន÷ ក្របខណ្ឌស្ថាប័ន ក្របខណ្ឌបច្ចេកទេស និងក្របខណ្ឌបញ្ញត្តិកម្ម។ ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល នឹងរួមចំណែកក្នុងការសម្រេចឱ្យបានកាន់តែរលូននូវសូចនាករគន្លឹះចំនួន២ គឺ÷ ១). **អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនឹងត្រូវឈានដល់ប្រមាណ ២%** និង ២). **ដង់ស៊ីតេធានារ៉ាប់រងប្រមាណ ៤០ ដុល្លារអាម៉េរិក សម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០២៥** ដែលជាចំណោលបង្គោលចរសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវសូចនាករគន្លឹះគោលដៅចុងក្រោយ ដូចបានដាក់ចេញក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០។

នៅចុងបញ្ចប់ តាងនាមឱ្យក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងរូបខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់និយ័តករធានារ៉ាប់រងកម្ពុជា ដែលបានរៀបចំ "ផែនការសកម្មភាពការងារសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥ របស់ **ន.ធ.ក.**" ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមកោតសរសើរចំពោះ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និង **ឯកឧត្តម ប៊ូ ច័ន្ទសិរី** អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា ព្រមទាំងក្រុមការងារបច្ចេកទេស និងភាគី

ពាក់ព័ន្ធទាំងអស់ ដែលបានដឹកនាំនិងចូលរួមធ្វើឱ្យផែនការនេះសម្រេចបានដោយជោគជ័យ និងក្លាយជាសមិទ្ធផលថ្មីមួយបន្ថែមទៀត សម្រាប់ការអនុវត្តដោយឈរលើស្មារតីទទួលខុសត្រូវ ភាពជាម្ចាស់ និងប្រសិទ្ធភាពខ្ពស់។

ថ្ងៃ ព្រហស្បតិ៍ ២ កើត ខែ មិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអភិបាលអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

## ផ្នែកទី១៖ សេចក្តីផ្តើម

បន្ទាប់ពីមានភាពធូរស្រាលនៃការឆ្លងរាលដាលជំងឺកូវីដ-១៩ តាមរយៈការសម្រេចបាននូវ “**ភាពស៊ាំសហគមន៍**” យ៉ាងឆាប់រហ័ស រាជរដ្ឋាភិបាលកម្ពុជាកំពុងជំរុញវិធានការស្តារសេដ្ឋកិច្ចឡើងវិញ ដើម្បីទទួលបាននូវកំណើនសេដ្ឋកិច្ចរឹងមាំ។ បញ្ហាសកលមួយចំនួនដូចជា ការបន្តអូសបន្លាយនៃវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ភាពមិនច្បាស់លាស់នៃទីផ្សារហិរញ្ញវត្ថុសកល និងការប្រកួតប្រជែងផ្នែកភូមិសាស្ត្រនយោបាយរបស់មហាអំណាចនៅអាស៊ីប៉ាស៊ីហ្វិក បានជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបានត្រឹមប្រមាណ ៥,២% ក្នុងឆ្នាំ២០២២ ដែលជាអត្រាមួយទាបជាងការរំពឹងទុក។ ដោយឡែក សម្រាប់ឆ្នាំ២០២៣ ផ្អែកតាមការព្យាករណ៍ អត្រាកំណើនសេដ្ឋកិច្ចកម្ពុជានឹងបន្តរក្សាបាននិន្នាការកើនឡើង ដោយស្ថិតក្នុងអត្រាកំណើនប្រមាណ ៥,៦%។

ការជំរុញការកសាងភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ គឺជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយក្នុងនោះការបន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធបច្ចេកវិទ្យាហិរញ្ញវត្ថុ និងសមត្ថភាពនៃប្រព័ន្ធហិរញ្ញវត្ថុឱ្យកាន់តែមានពិពិធភាព រឹងមាំ ធន់នឹងវិបត្តិ និងប្រកបដោយបរិយាប័ន្ន គឺជាវិធានការដែលបាននិងកំពុងអនុវត្ត។ ជាក់ស្តែង សក្តានុពលនៃបរិវត្តកម្មឌីជីថលបានជំរុញកម្ពុជា ឱ្យចាប់យកកាលានុវត្តភាពនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) ដើម្បីបន្តពង្រឹងការចូលរួមបង្កើនផលិតភាពសេដ្ឋកិច្ចជាតិ និងការពង្រឹងការផ្តល់សេវាហិរញ្ញវត្ថុ ទាំងផ្នែកសេវាធនាគារ និងមិនមែនធនាគារ។

ក្នុងសេវាហិរញ្ញវត្ថុមិនមែនធនាគារ វិស័យធានារ៉ាប់រងកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ក្នុងនោះ កំណើនបុព្វលាភធានារ៉ាប់រងដុលរបស់កម្ពុជាមានប្រមាណ ៣៣២ លានដុល្លារអាមេរិក, ទ្រព្យសកម្មសរុបនៃទីផ្សារធានារ៉ាប់រងមានប្រមាណ ៩៧៨ លានដុល្លារអាមេរិក ខណៈដែលមូលនិធិភាគហ៊ុនិកសរុបមានប្រមាណ ៤០៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២២។ ប្រការនេះបានបង្ហាញឱ្យឃើញនូវសក្តានុពលនៃមូលធនសាច់ប្រាក់ពីវិស័យធានារ៉ាប់រងផងដែរ សម្រាប់រួមចំណែកក្នុងការវិនិយោគក្នុងស្រុក ក្នុងន័យគាំទ្រកំណើនសេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ វិស័យធានារ៉ាប់រងបានរួមចំណែកក្នុងសេដ្ឋកិច្ចក្នុងអត្រាប្រមាណ

១,១៧% ជាមួយនឹងដង់ស៊ីតេធានារ៉ាប់រងប្រមាណ ២០,៥៣ ដុល្លារអាម៉េរិកក្នុងមនុស្សម្នាក់ សម្រាប់ឆ្នាំ ២០២២។

ជាការឆ្លើយតបទៅនឹងការអភិវឌ្ឍនៃវិស័យធានារ៉ាប់រងយ៉ាងឆាប់រហ័ស និងការបន្តកើនឡើងនៃតម្រូវការសេវាធានារ៉ាប់រងនៅកម្ពុជា ឯកសារសំខាន់ៗមួយចំនួនត្រូវបានដាក់ចេញឱ្យប្រើប្រាស់ជាបន្តបន្ទាប់ ក្នុងនោះមាន **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០”** ដែលទទួលបានការអនុម័តនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ និង **“ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥”** ដែលទទួលបានការអនុម័ត នៅថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២។ ផែនការទាំងនេះរៀបចំឡើងស្របតាមទិសដៅគោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងន័យគាំទ្រនិងជំរុញពិពិធកម្មផលិតផលហិរញ្ញវត្ថុនៅក្នុងវិស័យហិរញ្ញវត្ថុ ផ្អែកតាមឯកសារយុទ្ធសាស្ត្រនិងគោលនយោបាយជាតិគន្លឹះមួយចំនួន ដូចជា÷ **“យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤”**, **“ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣”**, **“យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥”**, និង **“ចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០៣០”**។

ក្នុងន័យនេះ ដើម្បីសម្រួលដល់ការអនុវត្តសកម្មភាពការងារជាក់ស្តែងប្រចាំឆ្នាំនីមួយៗ ស្របតាមទិសដៅនៃផែនការទាំងពីរខាងលើ និយ័តករធានារ៉ាប់រងកម្ពុជា (**ន.ធ.ក.**) សម្លឹងឃើញពីសារៈសំខាន់មិនអាចខ្វះបាន នៃការរៀបចំ តាមដាន និងកែសម្រួលជាប្រចាំលើផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ដើម្បីសម្របតាមដំណើរវិវត្តជាក់ស្តែងនៃទីផ្សារធានារ៉ាប់រង និងធនធានមានកម្រិតរបស់ **ន.ធ.ក.** ក៏ដូចជាកត្តាខាងក្រៅផ្សេងទៀត។ ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលរបស់ **ន.ធ.ក.** (២០២៣-២០២៥) គឺជាឯកសាររស់កំណែទី២ បន្ទាប់ពីបានអនុវត្តនូវផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលរបស់ **ន.ធ.ក.** (២០២២-២០២៤) និងត្រូវបានរៀបចំឡើងដោយយកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់ **ន.ធ.ក.** ២០២១-២០២៥ ធ្វើជាមូលដ្ឋានគ្រឹះ និងផ្អែកលើក្របខណ្ឌសំខាន់ៗចំនួន៣ រួមមាន÷ ក្របខណ្ឌស្ថាប័ន ក្របខណ្ឌបច្ចេកទេស និងក្របខណ្ឌបញ្ញត្តិកម្ម។ ក្នុងន័យនេះ ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល នឹងរួមចំណែកក្នុងការសម្រេចឱ្យបានកាន់តែរលូននូវសូចនាករគន្លឹះ

(Key Performance Indicators) ចំនួន២ គឺ៖ ១). អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ច (Insurance Penetration Rate) នឹងត្រូវឈានដល់ប្រមាណ ២% និង ២). ដង់ស៊ីតេធានារ៉ាប់រង (Insurance Density Rate) ប្រមាណ ៤០ ដុល្លារអាមេរិក សម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០២៥ ដែលជាចំណោលបង្គោលចរសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវសូចនាករគន្លឹះគោលដៅចុងក្រោយដូចបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០។

# ផ្នែកទី២៖ និយ័តករធានារ៉ាប់រងកម្ពុជា

## ២.១. រចនាសម្ព័ន្ធ

វិស័យធានារ៉ាប់រងដែលជាសសរស្តម្ភមួយក្នុងចំណោមវិស័យហិរញ្ញវត្ថុដទៃទៀត បាននិងកំពុងរីកចម្រើនក្នុងសន្ទុះគួរឱ្យកត់សម្គាល់ និងគួរជាទីមោទនៈ។ ស្របតាមការរីកចម្រើននេះ នាយកដ្ឋានធានារ៉ាប់រងនិងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រែក្លាយទៅជានិយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ យោងតាមច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" **ន.ធ.ក.** គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពក្រោមឱវាទផ្សេងទៀតរបស់ **អ.ស.ហ.** ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាសេនាធិការមួយរបស់ **អ.ស.ហ.** ដែលមានតួនាទីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យធានារ៉ាប់រង។ **ន.ធ.ក.** ត្រូវសិក្សានិងវិភាគលើមុខងារស្ថាប័នបច្ចុប្បន្ន ដើម្បីកែសម្រួលរចនាសម្ព័ន្ធស្ថាប័នផ្អែកលើភាពចាំបាច់ក្នុងន័យឆ្លើយតបនឹងការអភិវឌ្ឍវិស័យធានារ៉ាប់រង និងធានាបាននូវប្រសិទ្ធភាពនៃការបំពេញមុខងារនិងតួនាទីរបស់ខ្លួន។

### ២.២. ធនធានមនុស្ស

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តតួនាទី និងភារកិច្ចរបស់ស្ថាប័ន កត្តាធនធានមនុស្សដើរតួនាទីចម្បងជាកម្លាំងអូសទាញទៅរកភាពជោគជ័យ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ **ន.ធ.ក.** មានថ្នាក់ដឹកនាំ និងមន្ត្រីសរុបទាំងអស់ចំនួន ៥៦ រូប ដែលក្នុងនោះមានថ្នាក់ដឹកនាំនិយ័តករចំនួន ៣រូប ថ្នាក់ដឹកនាំនាយកដ្ឋានចំនួន ៥រូប ថ្នាក់ដឹកនាំការិយាល័យចំនួន ៦រូប និងមន្ត្រីចំនួន ៤២រូប។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនឥតឈប់ឈរនៃទីផ្សារធានារ៉ាប់រង និងការកើនឡើងនៃទំហំការងាររបស់និយ័តករក្នុងការបំពេញតួនាទីគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារធានារ៉ាប់រង **ន.ធ.ក.** នឹងផ្តោតលើផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដែលមានលក្ខណៈច្បាស់លាស់និងស៊ីជម្រៅដោយមានសមាសភាពចម្បងបីគឺ÷ (១)ការជ្រើសរើសមន្ត្រីថ្មីចំនួនប្រមាណ ៨០រូប ក្នុងរយៈពេល ៣ឆ្នាំ (២០២១-២០២៣) និងការជ្រើសរើសមន្ត្រីបន្ថែមទៀតក្នុងឆ្នាំ២០២៤ ដើម្បីបំពេញមុខងាររបស់ស្ថាប័នដែលនៅខ្វះចន្លោះ (២)ការបណ្តុះបណ្តាលមន្ត្រីទាំងនៅក្នុង និងក្រៅប្រទេស ដើម្បីធានាបាននូវគុណភាពខ្ពស់ និង (៣)ការផ្តល់ការលើកទឹកចិត្ត សមស្រប ដែលអាចប្រកួតប្រជែងក្នុងទីផ្សារការងារ។

## ផ្នែកទី៣÷ ចក្ខុវិស័យ គោលបំណង និងគោលដៅ

**ន.ធ.ក.** មានចក្ខុវិស័យក្លាយជាស្ថាប័ននៃឧត្តមភាព ក្នុងការធានាបាននូវភាពរឹងមាំនិងឧត្តមភាពប្រកួតប្រជែងប្រកបដោយចីរភាពរបស់គ្រឹះស្ថានធានារ៉ាប់រងទាំងអស់ ដើម្បីបម្រើដល់ពលរដ្ឋកម្ពុជាគ្រប់រូប និងជំរុញកំណើនសេដ្ឋកិច្ចជាតិ ស្របតាមចក្ខុវិស័យរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ន.ធ.ក.** បានកំណត់និងដាក់ចេញនូវអាទិភាពក្នុងការកសាងស្ថាប័នឱ្យមានសមត្ថភាពនិងគុណវុឌ្ឍិគ្រប់គ្រាន់ និងក្លាយខ្លួនជាស្ថាប័ននៃឧត្តមភាព ដោយផ្តោតលើ “សមត្ថភាពនិងជំនាញវិជ្ជាជីវៈ” “ភាពសកម្មនិងបុរេសកម្ម” និង “ភាពស្អាតស្អំនិងសុចរិតភាព”។

ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥ របស់ **ន.ធ.ក.** ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីកំណត់សកម្មភាពការងារលម្អិត កែសម្រួលសកម្មភាពការងារតាមភាពជាក់ស្តែង និងតម្រង់ទិសដៅឱ្យស្របតាមការអភិវឌ្ឍនៃទីផ្សារធានារ៉ាប់រងក្នុងឆ្នាំ២០២៣ តាមរយៈការពិនិត្យឡើងវិញលើ

សមិទ្ធផលការងារសំខាន់ៗដែលសម្រេចបាន ក៏ដូចជាកាលានុវត្តភាពថ្មីៗ និងបញ្ហាប្រឈមដែលកើតមានក្នុងឆ្នាំ២០២២ កន្លងមក។

គោលដៅដ៏សំខាន់ៗនៃផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលនេះ គឺជំរុញការអនុវត្តសកម្មភាពការងារប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងសង្គតិភាព សំដៅធ្វើយ៉ាងណាសម្រេចបាននូវសូចនាករគន្លឹះឆ្នាំ២០២៥ និងឆ្នាំ២០៣០។ ក្នុងន័យនេះ ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល បានដាក់ចេញនូវការទទួលខុសត្រូវរហូតដល់កម្រិតនាយកដ្ឋានជំនាញនីមួយៗនៃ **ន.ធ.ក.** ដែលនឹងសម្រួលដល់យន្តការត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ។

## ផ្នែកទី៤÷ គុណតម្លៃស្ថាប័ន

**ន.ធ.ក.** ប្រកាន់យកគុណតម្លៃស្ថាប័នចំនួន៦ រួមមាន÷ ១.ក្រមសីលធម៌វិជ្ជាជីវៈ, ២.ស្មារតីបុរេសកម្ម, ៣.ប្រតិគុល្យការ, ៤.ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព, ៥.នវានុវត្តន៍, ៦.គុណាធិបតេយ្យ ដែលស្របតាមចក្ខុវិស័យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឆ្នាំ២០៣០។

- **ក្រមសីលធម៌វិជ្ជាជីវៈ÷** ការប្រតិបត្តិតាមគោលការណ៍សីលធម៌ ដែលកំណត់នូវសកម្មភាព និងអាកប្បកិរិយាក្នុងពេលបំពេញការងារ ដើម្បីរក្សាគុណតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូរ នៃមន្ត្រីរាជការ តាមរយៈការប្រកាន់ខ្ជាប់ឆន្ទៈម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងវប្បធម៌សេវាសាធារណៈ ព្រមទាំងគោរពបានយ៉ាងខ្ជាប់ខ្ជួននូវអភិក្រម ៤ប្រការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- **ស្មារតីបុរេសកម្ម÷** ការគិតយល់មុននូវលទ្ធភាពកើតមានបញ្ហា ការប្រកាន់យកគោលការណ៍មិនបង្កើតបញ្ហា ការរៀបចំប្រព័ន្ធការងារដែលកាត់បន្ថយលទ្ធភាពកើតមានបញ្ហា ការត្រៀមលក្ខណៈសកម្មជានិច្ចត្រៀមដោះស្រាយបញ្ហាជាយថាហេតុ ការមិនមើលបំណាំ មិនចោទប្រកាន់គ្នា និងការគិតគូរដោះស្រាយបញ្ហាទាន់នៅទំហំតូច ចាត់វិធានការជាមុនដោយមិនរង់ចាំការណែនាំ។
- **ប្រតិគុល្យការ÷** ការពិចារណា ថ្លឹងថ្លែង បែងចែកតួនាទី ភារកិច្ច និងសិទ្ធិសម្រេច ប្រកបដោយយុត្តិធម៌ ដើម្បីធ្វើឱ្យថ្នាក់ដឹកនាំអង្គភាព និងមន្ត្រីគ្រប់លំដាប់ថ្នាក់មានលំនឹងចិត្ត ការជឿជាក់ និងការទទួល

ខុសត្រូវច្បាស់លាស់ ក្នុងការអនុវត្តតួនាទី ភារកិច្ច ដោយឈរលើមាគ៌ាសុចរិត យុត្តិធម៌ បម្រើឧត្តមប្រយោជន៍ជាតិ និងប្រជាជន។

- **ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព÷** ការផ្តោតការយកចិត្តទុកដាក់លើគុណភាពនៃលទ្ធផល ភាពសមស្របនៃចំណាយ និងវិធីសាស្ត្រប្រតិបត្តិការ ដោយប្រកាន់ជំហរ "គិតត្រូវ ធ្វើត្រូវ ចំណាយតិច បានផលអតិបរមា"។

- **នវានុវត្តន៍÷** ការប្រើគំនិតកែច្នៃ និងការចូលរួមដោះស្រាយបញ្ហាប្រឈមជាក់ស្តែង តាមរយៈការបង្កើតដំណោះស្រាយថ្មី ឬការច្នៃប្រឌិតលើស្នាដៃដែលមានស្រាប់ដែលបង្កើតជាតម្លៃបន្ថែម។

- **គុណាធិបតេយ្យ÷** ប្រព័ន្ធលើកទឹកចិត្តសមស្រប ផ្អែកលើសមត្ថភាព សមិទ្ធកម្ម ប្រសិទ្ធភាព វិន័យ នវានុវត្តន៍ និងសមធម៌ ដែលធានាសុចរិតភាព និរន្តភាព និងកិត្យានុភាពស្ថាប័ន តាមគោលការណ៍លើកទឹកចិត្តផ្អែកលើគុណសម្បត្តិ និងបង្កើតគុណសម្បត្តិដើម្បីបានការលើកទឹកចិត្ត។

## ផ្នែកទី៥÷ សមិទ្ធផលនិងបញ្ហាប្រឈមក្នុងឆ្នាំ២០២២

បន្ទាប់ពីមានការធូរស្រាលពីវិបត្តិកូវីដ-១៩ **ន.ធ.ក.** ក្នុងឆ្នាំ២០២២ បានបន្តសកម្មភាពការងាររបស់ខ្លួនសំដៅបង្កើនសមត្ថភាពស្ថាប័នក្នុងការគ្រប់គ្រងរដ្ឋបាលនិងធនធានមនុស្ស ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការ ការពារអតិថិជន ការធ្វើបញ្ញត្តិកម្ម ជំរុញកំណើនទីផ្សារ នវានុវត្តនិងពិពិធកម្មផលិតផលនិងសេវាកម្ម ការលើកកម្ពស់បរិយាបន្ន ការលើកកម្ពស់ការយល់ដឹងរបស់សាធារណជននិងអក្ខរកម្មធានារ៉ាប់រង ក៏ដូចជាធានាប្រតិបត្តិការទីផ្សារប្រកបដោយសុចរិតភាព ភាពប្រកួតប្រជែង និងប្រសិទ្ធភាព។ ក្នុងន័យនេះ សមិទ្ធផលសកម្មភាពការងាររបស់ **ន.ធ.ក.** ជារួមអាចបែងចែកតាមក្របខណ្ឌនីមួយៗដូចជា÷ ក្របខណ្ឌស្ថាប័ន ក្របខណ្ឌបច្ចេកទេស និងក្របខណ្ឌបញ្ញត្តិកម្ម ក៏ដូចជាវឌ្ឍនភាពនៃសូចនាករគន្លឹះក្នុងឆ្នាំ២០២២ និងបញ្ហាប្រឈមរបស់ **ន.ធ.ក.**។

## ៥.១. ក្រុមខណ្ឌស្ថាប័ន

ការបង្កើតស្ថាប័ន **ន.ធ.ក.** នាដើមឆ្នាំ២០២១ គឺជាចំណុចរបត់ដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍវិស័យធានារ៉ាប់រងនៅកម្ពុជា ក៏ដូចជាការពង្រឹងតួនាទីនិយ័តកម្មទីផ្សារធានារ៉ាប់រងកម្ពុជាផងដែរ។ ក្នុងន័យនេះ ជាលទ្ធផលក្នុងការបំពេញតួនាទីនិងភារកិច្ចដែលបានប្រគល់ជូន រហូតមកដល់បច្ចុប្បន្ន **ន.ធ.ក.** សម្រេចបាននូវសមិទ្ធផលការងារជាយុទ្ធសាស្ត្រមួយចំនួន ដូចជា “**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០**” ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នាថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១ និង “**ផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥**” ដែលត្រូវបានក្រុមប្រឹក្សា **អ.ស.ហ.** អនុម័តកាលពីថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២២។

ក្នុងក្របខណ្ឌស្ថាប័ន នៅឆ្នាំ២០២៣ **ន.ធ.ក.** បានរៀបចំបំពាក់សម្ភារៈការិយាល័យ និងឧបករណ៍ព័ត៌មានវិទ្យានៅអគារ **អ.ស.ហ.** ជាន់ទី៦ សម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រីនៃ **ន.ធ.ក.** បានរួចរាល់ជាស្ថាពរ។ លើសពីនេះ ប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) ដំណាក់កាលទី២ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី២ ក៏ត្រូវបានរៀបចំនិងដាក់ឱ្យដំណើរការផងដែរ។ បន្ថែមពីនេះ **ន.ធ.ក.** សម្រេចបាននូវប្រព័ន្ធលើកទឹកចិត្តដល់មន្ត្រី **ន.ធ.ក.** សម្រាប់ដំឡើងឋានន្តរស័ក្តិ និងផ្តល់ប្រាក់ឧបត្ថម្ភប្រាក់រង្វាន់ដល់មន្ត្រីនៃ **ន.ធ.ក.**។ ជាមួយនេះផងដែរ មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសរុបចំនួន ១៤រូប ត្រូវបានជ្រើសរើសចូលបម្រើការងារនៅ **ន.ធ.ក.** ដើម្បីបំពេញតម្រូវការធនធានមនុស្សឱ្យស្របតាមទំហំការងារជាក់ស្តែង។

## ៥.២. ក្របខណ្ឌបច្ចេកទេស

ជាក្របខណ្ឌបច្ចេកទេស **ន.ធ.ក.** បានបន្តអនុវត្តយន្តការត្រួតពិនិត្យដល់ទីកន្លែងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង និងពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមទំហំនៃហានិភ័យរបស់

ក្រុមហ៊ុន (កម្រិត១) (Solvency I or Risked-Based Capital-RBC I) ព្រមទាំងរៀបចំរបាយការណ៍ប្រចាំគ្រាសម្រាប់គ្រឹះស្ថានធានារ៉ាប់រង។

លើសពីនេះ **ន.ធ.ក.** បានបន្តពង្រឹងការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ (Market Conduct Examination Procedure Manual) ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការអនុវត្តយន្តការផ្សះផ្សាវិវាទធានារ៉ាប់រងក្នុងកិច្ចការពារអតិថិជន។ បន្ថែមពីនេះ **ន.ធ.ក.** បានបណ្តុះបណ្តាលមន្ត្រីជំនាញអំពីការអនុវត្តវិធីសាស្ត្រអនុវត្ត សម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រង និងវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យ និងបណ្តុះបណ្តាលគ្រឹះស្ថានធានារ៉ាប់រងអំពីទម្រង់របាយការណ៍ប្រចាំគ្រា ក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ។ សម្រាប់ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង **ន.ធ.ក.** បានពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង និងជំរុញការបំពេញមុខងារ និងតួនាទីរបស់សមាគមជើងសាធានារ៉ាប់រងកម្ពុជា។ ចំពោះការផ្សព្វផ្សាយ និងអប់រំសាធារណៈជន **ន.ធ.ក.** បានបន្តផ្សព្វផ្សាយស្ប៉តអប់រំអំពីសារប្រយោជន៍នៃការធានារ៉ាប់រងជាប្រចាំតាមទូរទស្សន៍និងប្រព័ន្ធបណ្តាញសង្គម ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងធានារ៉ាប់រង និងផ្សព្វផ្សាយជូនសាធារណជនអំពីខ្លឹមសារនៃផលិតផលធានារ៉ាប់រង និងអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រងនៅតាមបណ្តារាជធានី ខេត្ត ក្រុង ក៏ដូចជាចូលរួមកម្មវិធីកិច្ចពិភាក្សា ឬព្រឹត្តិការណ៍នានាដែលផ្សព្វផ្សាយអំពីការធានារ៉ាប់រង។

ទន្ទឹមនឹងនេះ **ន.ធ.ក.** ក៏បានជំរុញការអនុវត្តប្រកាសអន្តរក្រសួងពីការធានារ៉ាប់រងជាកាតព្វកិច្ច ព្រមទាំងរៀបចំឯកសារគោល ស្តីពីប្រព័ន្ធគ្រប់គ្រងការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តឯកជនជាកាតព្វកិច្ច។ ក្នុងនោះផងដែរ **ន.ធ.ក.** បានសិក្សារៀបចំបង្កើតអនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនគ្រប់គ្រងមូលនិធិធានារ៉ាប់រង និងបានធ្វើការសិក្សា ព្រមទាំងផ្តល់យោបល់ជាក្របខណ្ឌគោលនយោបាយអំពីផលិតផលធានារ៉ាប់រងបន្ថែម ដើម្បីដាក់ជាកាតព្វកិច្ចក្នុងគោលដៅចូលរួមទ្រទ្រង់ដល់ប្រព័ន្ធសន្តិសុខសង្គមផងដែរ។

### ៥.៣. ក្របខណ្ឌបញ្ញត្តិកម្ម

ក្នុងក្របខណ្ឌបញ្ញត្តិកម្ម **ន.ធ.ក.** បានកំពុងរៀបចំប្រកាសស្តីពី ការធានារ៉ាប់រងបន្ត និងធ្វើបច្ចុប្បន្នភាពប្រកាស ស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង។ បន្ថែមពីនោះ **ន.ធ.ក.** បាននឹងកំពុងរៀបចំប្រកាស ស្តីពីការលក់ផលិតផលធានារ៉ាប់រង តាមប្រព័ន្ធអេឡិចត្រូនិករៀបចំប្រកាស ស្តីពីការធ្វើទីផ្សារសម្រាប់ផលិតផលធានារ៉ាប់រង និងប្រកាសស្តីពីការការពារការក្លែងបន្លំ ក៏ដូចជារៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងទីផ្សារធានារ៉ាប់រង និងបន្តពង្រឹងអនុលោមភាពនៃលិខិតបទដ្ឋានគតិយុត្តជាធរមានជាអាទិ៍ ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងប្រកាសស្តីពីនីតិវិធីនៃការទទួលនិងដោះស្រាយបណ្តឹងធានារ៉ាប់រង។

### ៥.៤. សូចនាករគន្លឹះ

ជាលទ្ធផល ទីផ្សារធានារ៉ាប់រងក្នុងឆ្នាំ២០២២ បានបន្តកើនឡើងគួរឱ្យកត់សម្គាល់ ដោយមានចំនួនគ្រឹះស្ថានធានារ៉ាប់រងចំនួន ៧៩ក្រុមហ៊ុន ដែលក្នុងនោះមាន ៣៩ ក្រុមហ៊ុនធានារ៉ាប់រង, ១៥ ក្រុមហ៊ុនជើងសាធានារ៉ាប់រង និង ២៥ ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងដុលបានកើនឡើងពី ១៩៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៨ ដល់ប្រមាណ ៣៣២ លានដុល្លារអាម៉េរិក ក្នុងឆ្នាំ២០២២ ជាមួយនឹងអត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចកម្ពុជាប្រមាណជា ១,១៧% និងដង់ស៊ីតេធានារ៉ាប់រងចំនួន ២០,៥៣ ដុល្លារអាម៉េរិក សម្រាប់មនុស្សម្នាក់ៗ។

### ៥.៥. បញ្ហាប្រឈម

ជាក់ស្តែង ក្រៅពីសមិទ្ធផលនានាដែល **ន.ធ.ក.** សម្រេចបានក្នុងឆ្នាំ២០២២ បញ្ហាប្រឈមមួយចំនួនបានបន្តរំលេចឡើង ដែលក្នុងនោះរួមមានតម្រូវការធនធានមនុស្សដែលមានជំនាញវិជ្ជាជីវៈពាក់ព័ន្ធនឹងធានារ៉ាប់រងនិងបច្ចេកវិទ្យាធានារ៉ាប់រងនៅតែបន្តជាបញ្ហាប្រឈម បន្ថែមពីនោះតម្រូវការក្របខណ្ឌគតិ-យុត្តឱ្យបានគ្រប់គ្រាន់ដើម្បីឆ្លើយតបទៅនឹងសម្ទុះនៃការអភិវឌ្ឍវិស័យធានារ៉ាប់រង ព្រមទាំងភាពមានកម្រិតនៃការសហការក្នុងការបញ្ជ្រាបការយល់ដឹងពីវិស័យធានារ៉ាប់រង ស្របពេលតម្រូវការកន្លែងធ្វើការបន្ថែមឆ្លើយតបនឹងកំណើននៃចំនួនមន្ត្រី។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមនេះ ស្របនឹងសម្ទុះនៃការអភិវឌ្ឍ

វិស័យធានារ៉ាប់រង **ន.ធ.ក.** បានជ្រើសរើសមន្ត្រីដែលមានជំនាញវិជ្ជាជីវៈពាក់ព័ន្ធបន្ថែម ក៏ដូចជាបន្តសាង-សង់អាគាររដ្ឋបាលបន្ថែមឱ្យបានសមស្របទៅនឹងតម្រូវការចាំបាច់ជាក់ស្តែង ព្រមទាំងបង្កើនប្រសិទ្ធភាព និងគុណវុឌ្ឍិរបស់មន្ត្រីក្នុងការបំពេញមុខងារ និងតួនាទី, បន្តរៀបចំ និងដាក់ចេញជាបន្តបន្ទាប់នូវបទប្បញ្ញត្តិពាក់ព័ន្ធ, និងបន្តជំរុញនិងលើកទឹកចិត្តវិស័យឯកជន។

## ផ្នែកទី៦÷ ផែនការសកម្មភាពបីឆ្នាំរំកិល ២០២៣-២០២៥

ជាអភិក្រមនៃការរៀបចំផែនការសកម្មភាពបីឆ្នាំរំកិលនេះ **ន.ធ.ក.** បានកំណត់សកម្មភាពការងារដែលត្រូវអនុវត្តក្រោមក្របខណ្ឌចំនួន ៣ ផ្សេងៗគ្នា ក្នុងរយៈពេល ៣ឆ្នាំ (២០២៣-២០២៥) ដែលមានដូចខាងក្រោម÷ **ទី១. ក្របខណ្ឌស្ថាប័ន** (សមត្ថភាពស្ថាប័ន, ការតភ្ជាប់ និងកិច្ចសហប្រតិបត្តិការ) **ទី២. ក្របខណ្ឌបច្ចេកទេស** (ការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ, ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ, កិច្ចការពារអតិថិជន, ការផ្តល់អាជ្ញាបណ្ណ, ការចុះបញ្ជីគ្រឹះស្ថានធានារ៉ាប់រង, ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង, ការផ្សព្វផ្សាយនិងការអប់រំសាធារណជន និងការធានារ៉ាប់រងជាកាតព្វកិច្ច) និង**ទី៣. ក្របខណ្ឌបញ្ញត្តិកម្ម** (ការកែសម្រួលបទប្បញ្ញត្តិចាស់ និងការរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិថ្មី)។

ក្រៅពីនេះ **ន.ធ.ក.** បាននឹងកំពុងយកចិត្តទុកដាក់ផងដែរ លើដំណើរវិវត្តន៍របស់និន្នាការសកលនៃវិស័យធានារ៉ាប់រងឈានទៅរកបរិវត្តកម្មស៊ីជម្រៅ ដែលអាចមានឥទ្ធិពលមួយចំនួនលើទីផ្សារធានារ៉ាប់រងនៅកម្ពុជា។ ការណ៍នេះអាចអនុញ្ញាតឱ្យ **ន.ធ.ក.** មានលទ្ធភាពក្នុងការងារចាត់ចែងធនធាន សកម្មភាពការងារ ក៏ដូចជាវិធានការរបស់ខ្លួនសមស្របជាជំហានៗ។

### ៦.១. និន្នាការសកលនៃវិស័យធានារ៉ាប់រង

និន្នាការសកល ជារួម សំដៅដល់កម្លាំងរុញច្រានឆ្ពោះទៅរកការផ្លាស់ប្តូររូបរាងជាដុំកំភួនលើស្ថានភាពបច្ចុប្បន្នរបស់សកល ដែលមានភាពជាប់ទាក់ទងយ៉ាងស៊ីជម្រៅលើគំរូឧស្សាហកម្មទាំងអស់ មានឥទ្ធិពលលើអនាគតនៃទីផ្សារ និងបង្កើតបានជាតម្រូវការនិងការផ្គត់ផ្គង់គំរូថ្មី ក៏ដូចជាអាចនឹងបង្កើតបានជា

ហានិភ័យនិងកាលានុវត្តភាពដំណាលគ្នា ដែលការណ៍នេះទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើអាទិភាពការងារជាក់ស្តែង។

ក្នុងន័យនេះ និន្នាការសកលនៃវិស័យធានារ៉ាប់រងកំពុងមានបម្រែបម្រួលស៊ីជម្រៅ ដោយបានផ្សារភ្ជាប់ទៅនឹងទិសដៅអនាគតនៃទីផ្សារធានារ៉ាប់រង ក្នុងរង្វង់រយៈពេលពីមធ្យមទៅវែង។ ផ្អែកតាមការសិក្សារបស់ PwC[1] បានលើកឡើងថា និន្នាការសកលសំខាន់ៗនៃវិស័យធានារ៉ាប់រងមានចំនួន៥ ដែលកំពុងមានឥទ្ធិពលលើអនាគតនៃវិស័យធានារ៉ាប់រងក្នុងកម្រិតពិភពលោក ព្រមទាំងជាកម្លាំងរុញច្រាននិងកំណត់ជារូបរាងនៃទីផ្សារធានារ៉ាប់រង ក្នុងរយៈពេល ៥ឆ្នាំខាងមុខនិង/ឬលើសពីនេះ។

- **និន្នាការទី១÷ គម្លាតជំនឿទុកចិត្តកាន់តែធំជាងមុន**។ ការធ្លាក់ចុះនៃជំនឿទុកចិត្ត រួមទាំងកង្វះខាតការអប់រំផ្នែកហិរញ្ញវត្ថុ បានបង្កការលំបាកដែលជំរុញឱ្យអតិថិជនប្រើប្រាស់សេវាធានារ៉ាប់រងកាន់តែតិចជាងមុន គម្លាតកាន់តែធំជាងមុន និងខាតបង់សេដ្ឋកិច្ចកាន់តែខ្ពស់។ ការណ៍នេះតម្រូវឱ្យមាននូវយុទ្ធ-សាស្ត្រច្បាស់លាស់ ក្នុងការដោះស្រាយបញ្ហាជំនឿទុកចិត្ត តាមរយៈការអប់រំផ្សព្វផ្សាយ បង្កើតផលិតផលដែលមានតម្លៃសមស្រប (ធានារ៉ាប់រងខ្នាតតូច) និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធចែកចាយទៅដល់អតិថិជន។
- **និន្នាការទី២÷ តម្រូវការនិងការចង់បានរបស់អ្នកប្រើប្រាស់សេវាធានារ៉ាប់រង មានការប្រែប្រួលយ៉ាងឆាប់រហ័ស**។ អ្នកប្រើប្រាស់សេវាធានារ៉ាប់រងបច្ចុប្បន្ន សម្លឹងទៅកាន់ការធានារ៉ាប់រងលើសពី ការការពារបន្ទុកហិរញ្ញវត្ថុ ដែលអាចធ្វើការកែសម្រួលបានតាមតម្រូវការជាក់ស្តែងរបស់ខ្លួន (personalize) ដូចជា សម្រាប់ការរស់នៅប្រចាំថ្ងៃ ការទិញរថយន្ត ផែនការចូលនិវត្តន៍ និងការវិនិយោគលើធុរកិច្ចជាដើម។ ចំណុចនេះទាមទារឱ្យមានការវិនិយោគលើបច្ចេកវិទ្យាឌីជីថល ដើម្បីប្រមូលទិន្នន័យយ៉ាងសម្បើមសម្រាប់វិភាគ និងរៀបចំផលិតផលធានារ៉ាប់រងស្របតាមតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់។
- **និន្នាការទី៣÷ កំណើននៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនិងបញ្ញាសិប្បនិមិត្ត**។ ការច្នៃប្រឌិតឌីជីថល និងការធ្វើបរិវត្តកម្មឌីជីថល កំពុងបន្តផ្លាស់ប្តូររូបរាងទម្រង់ហានិភ័យនៃវិស័យធានារ៉ាប់រងជាមួយនឹងការបង្កើតនូវកាលានុវត្តភាពថ្មីៗផងដែរ។ បច្ចេកវិទ្យាទំនើបៗកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស

[1] PwC, 2022, Insurance Reimagined: Spotlight on Trust, Convergence, and Transformation, Insurance 2025 and Beyond

និងបាននាំមកនូវផលិតផលបច្ចេកវិទ្យាថ្មីៗមួយចំនួនដូចជា រថយន្តគ្មានមនុស្សបើក រោងចក្រស្វ័យប្រវត្តិ ការប្រើប្រាស់ឧបករណ៍សែនស័រ និងរូបិយបណ្ណឌីជីថលជាដើម។ ផ្អែកលើការវាយតម្លៃរបស់អង្គការសហប្រជាជាតិ ក្នុងរបាយការណ៍បច្ចេកវិទ្យានិងការច្នៃប្រឌិតឆ្នាំ២០២១ ការចាប់យកបច្ចេកវិទ្យាចុងក្រោយនឹងក្លាយជាកត្តាជំរុញទីផ្សារឱ្យរីកចម្រើន ៩ដងនៅឆ្នាំ២០២៥។

- **<u>និន្នាការទី៤÷ ហានិភ័យអាកាសធាតុនិងការផ្តោតសំខាន់លើចីរភាព</u>។** ការកើនឡើងនៃភាពគំរាមគំហែងបណ្តាលមកការប្រែប្រួលអាកាសធាតុ បានបង្កើតជាហានិភ័យជាប្រព័ន្ធដល់ធានារ៉ាប់រងដោយផ្ទាល់។ ដើម្បីប្រឆាំងនិងការពារលើហានិភ័យទាំងនេះ ទាមទារឱ្យមានការពង្រឹងការយល់ដឹងពីបញ្ហាទាំងនេះ ការបង្កើតផលិតផលនិងសេវាពាក់ព័ន្ធនឹងអាកាសធាតុ ការកសាងគំរូវាយតម្លៃហានិភ័យនិងការកំណត់បុព្វលាភ និងផែនការការងារសម្រាប់កាត់បន្ថយហានិភ័យ។

- **<u>និន្នាការទី៥÷ ភាពប្រសព្វគ្នា កិច្ចសហការ និងការប្រកួតប្រជែង</u>។** កិច្ចសហការល្អប្រសើររវាងស្ថាប័ននិងតួអង្គពាក់ព័ន្ធក្នុងវិស័យធានារ៉ាប់រង ក្នុងការចែករំលែកទិន្នន័យក្នុងវិស័យ គឺជាមធ្យោបាយថ្មីនិងការបង្កើតតម្លៃបន្ថែម និងតម្រូវឱ្យមានការវិនិយោគយ៉ាងច្រើនលើមូលដ្ឋានគ្រឹះឌីជីថលដូចជា ប្រព័ន្ធអេកូឡូស៊ី និងទីផ្សារជាដើម។ ក្នុងន័យនេះ គ្រប់តួអង្គពាក់ព័ន្ធក្នុងវិស័យធានារ៉ាប់រង ត្រូវពិចារណាឡើងវិញពីភាពជាដៃគូនិងកិច្ចសហប្រតិបត្តិការ ដែលលើសពីវិធីសាស្ត្រជាប្រពៃណី ដើម្បីនាំមកនូវការផ្លាស់ប្តូរ។

ដើម្បីជម្នះបញ្ហាប្រឈមនិងទាញយកកាលានុវត្តភាពថ្មីៗ សម្រាប់អភិវឌ្ឍន៍ទីផ្សារធានារ៉ាប់រង គ្រប់តួអង្គក្នុងវិស័យធានារ៉ាប់រងត្រូវប្រមូលផ្តុំធនធានមនុស្សប្រកបដោយជំនាញ ជំរុញការច្នៃប្រឌិតនិងបង្កើតថ្មីប្រើប្រាស់បច្ចេកវិទ្យាទំនើបៗ ពង្រឹងកិច្ចសហប្រតិបត្តិការ និងផ្អែកលើទស្សនសម្លឹងទៅមុខ។

## ៦.២. ក្របខណ្ឌស្ថាប័ន

### ៦.១.១. សមត្ថភាពស្ថាប័ន

#### ក. រចនាសម្ព័ន្ធស្ថាប័ន

វិស័យធានារ៉ាប់រងដែលជាសសរស្តម្ភមួយក្នុងចំណោមវិស័យហិរញ្ញវត្ថុដទៃទៀត បាននិងកំពុងរីកចម្រើនក្នុងសន្ទុះគួរឱ្យកត់សម្គាល់ និងគួរជាទីមោទនៈ។ ស្របតាមការរីកចម្រើននេះ នាយកដ្ឋានធានា-

រ៉ាប់រងនិងសោធន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ចំណុះឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានប្រែក្លាយទៅជានិយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ យោងតាមច្បាប់ស្តីពី "ការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" **ន.ធ.ក.** គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពក្រោមឱវាទផ្សេងទៀតរបស់ **អ.ស.ហ.** ត្រូវបានបង្កើតឡើងដើម្បីបំពេញមុខងារជាសេនាធិការមួយរបស់ **អ.ស.ហ.** ដែលមានតួនាទីគ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យធានារ៉ាប់រង។ **ន.ធ.ក.** ត្រូវសិក្សានិងវិភាគលើមុខងារស្ថាប័នបច្ចុប្បន្ន ដើម្បីកែសម្រួលរចនាសម្ព័ន្ធស្ថាប័នផ្អែកលើភាពចាំបាច់ក្នុងន័យឆ្លើយតបនឹងការអភិវឌ្ឍវិស័យធានារ៉ាប់រង និងធានាបាននូវប្រសិទ្ធភាពនៃការបំពេញមុខងារនិងតួនាទីរបស់ខ្លួន។

### ខ. អភិបាលកិច្ច

អភិបាលកិច្ចគឺជាដំណើរការនៃការដឹកនាំ និងគ្រប់គ្រងស្ថាប័នមួយដោយផ្អែកលើច្បាប់ និងបទប្បញ្ញត្តិជាធរមាន។ **ន.ធ.ក.** មានគោលដៅធានាបាននូវអភិបាលកិច្ចល្អ ដែលមានតួនាទីចម្បងក្នុងការសម្រេចបាននូវភាពជោគជ័យរបស់ស្ថាប័ន។ ក្នុងការដឹកនាំនិងគ្រប់គ្រង **ន.ធ.ក.** ការតែងតាំងថ្នាក់ដឹកនាំ និងមន្ត្រីរបស់ **ន.ធ.ក.** ត្រូវរៀបចំឡើងដើម្បីបែងចែកតួនាទី និងភារកិច្ចក្នុងការទទួលខុសត្រូវ ទាំងក្នុងកម្រិតនាយកដ្ឋាន កម្រិតការិយាល័យ និងកម្រិតមន្ត្រីជំនាញ ក្នុងគោលដៅធានាដំណើរប្រព្រឹត្តទៅរបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាពខ្ពស់។

### គ. ធនធានមនុស្ស

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តតួនាទី និងភារកិច្ចរបស់ស្ថាប័ន កត្តាធនធានមនុស្សដើរតួនាទីចម្បងជាកម្លាំងអូសទាញទៅរកភាពជោគជ័យ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ **ន.ធ.ក.** មានថ្នាក់ដឹកនាំ និងមន្ត្រីសរុបទាំងអស់ចំនួន ៥៦ រូប ដែលក្នុងនោះមានថ្នាក់ដឹកនាំនិយ័តករចំនួន ៣រូប ថ្នាក់ដឹកនាំនាយកដ្ឋានចំនួន ៥រូប ថ្នាក់ដឹកនាំការិយាល័យចំនួន ៦រូប និងមន្ត្រីចំនួន ៤២រូប។ ដើម្បីឆ្លើយតបនឹងការរីកចម្រើនឥតឈប់ឈរនៃទីផ្សារធានារ៉ាប់រង និងការកើនឡើងនៃទំហំការងាររបស់និយ័តករក្នុងការ

បំពេញតួនាទីគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារធានារ៉ាប់រង **ន.ធ.ក.** នឹងផ្តោតលើផែនការអភិវឌ្ឍន៍ធនធានមនុស្ស ដែលមានលក្ខណៈច្បាស់លាស់និងស៊ីជម្រៅដោយមានសមាសភាពចម្បងបីគឺ÷ (១)ការជ្រើសរើសមន្ត្រីថ្មីចំនួនប្រមាណ ៨០រូប ក្នុងរយៈពេល ៣ឆ្នាំ (២០២១-២០២៣) និងការជ្រើសរើសមន្ត្រីបន្ថែមទៀតក្នុងឆ្នាំ២០២៤ ដើម្បីបំពេញមុខងាររបស់ស្ថាប័នដែលនៅខ្វះចន្លោះ (២)ការបណ្តុះបណ្តាលមន្ត្រីទាំងនៅក្នុងនិងក្រៅប្រទេស ដើម្បីធានាបាននូវគុណភាពខ្ពស់ និង (៣)ការផ្តល់ការលើកទឹកចិត្ត សមស្រប ដែលអាចប្រកួតប្រជែងក្នុងទីផ្សារការងារ។

### ឃ. បរិស្ថាននិងលក្ខខណ្ឌការងារ

បច្ចុប្បន្ន **ន.ធ.ក.** មានទីតាំងស្ថិតនៅជាន់ទី៦ នៃអគារលេខ ១៦៨ F លើបណ្តោយផ្លូវលេខ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ ផ្អែកតាមស្ថានភាពនិងទំហំជាក់ស្តែងនៃទីកន្លែងសម្រាប់បំពេញការងារ **ន.ធ.ក.** អាចផ្ទុកចំនួនមន្ត្រីនិងថ្នាក់ដឹកនាំ សមល្មមប្រមាណ ៦០រូប តែប៉ុណ្ណោះ។ លើសពីនេះ ដើម្បីជួយបង្កើនប្រសិទ្ធភាពនៃការបំពេញការងាររបស់មន្ត្រី និងថ្នាក់ដឹកនាំ ប្រព័ន្ធគ្រប់គ្រងការងារ និងរំហូរឯកសារ ក៏គួរត្រូវបានធ្វើទំនើបកម្មតាមរយៈការវិនិយោគលើប្រព័ន្ធបច្ចេកវិទ្យាជាដំណាក់កាលៗ តាមលទ្ធភាពរបស់ស្ថាប័ន។

## ៦.១.២. ការតភ្ជាប់

### ក. ការតភ្ជាប់ផ្នែករឹង

កាតព្វកិច្ចក្នុងការពង្រឹងនិងពង្រីកផ្នែករឹងនៃការតភ្ជាប់របស់ **ន.ធ.ក.** គឺត្រូវផ្តោតលើការរៀបចំពង្រឹងសមត្ថភាពជំនាញ នៅក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា ដូចជារៀបចំពង្រឹងកម្មវិធីសិក្សាជំនាញធានា-រ៉ាប់រងកម្រិតឧត្តមសិក្សា ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា, រៀបចំវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ដោយសហការជាមួយសមាគមធានារ៉ាប់រងកម្ពុជា, សិក្សាសមិទ្ធិលទ្ធភាពស្តីពី គម្រោងសាងសង់សាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង, និងរៀបចំបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង។

### ខ. ការតភ្ជាប់ផ្នែកទន់

ជាមួយគ្នានេះដែរ ការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាឌីជីថល ក៏អាចជួយ **ន.ធ.ក.** ក្នុងការពង្រឹងនិងពង្រីកផ្នែកទន់នៃការតភ្ជាប់ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងការប្រមូលនិងគ្រប់គ្រងទិន្នន័យទីផ្សារ និងផ្តល់សេវាជូនទីផ្សារធានារ៉ាប់រងប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ តាមរយៈផែនការវិនិយោគដូចជា រៀបចំប្រព័ន្ធវិភាគនិងផ្តល់សញ្ញាមុន (Early Warning System) សម្រាប់វិភាគលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងផ្តល់ការព្រមាន, រៀបចំប្រព័ន្ធចុះបញ្ជីបុគ្គលភ្នាក់ងារធានារ៉ាប់រង (Insurance Agent Registration Management Information System-IARMIS) សម្រាប់គ្រប់គ្រង និងរក្សាទុកទិន្នន័យអំពីបុគ្គលភ្នាក់ងារធានារ៉ាប់រង, រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រឹះស្ថានធានារ៉ាប់រង (Company Profile Management Information System-CPMIS), រៀបចំប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យអំពីផលិតផលធានារ៉ាប់រងយានយន្ត (MTPL Data Collection and Management Information System), រៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) និងសិក្សាសមិទ្ធិលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រងក្នុងទីផ្សារធានារ៉ាប់រងកម្ពុជា និងក្នុងក្របខណ្ឌសមាហរណកម្មតំបន់។

## ៦.១.៣. កិច្ចសហប្រតិបត្តិការ

### ក. កិច្ចសហប្រតិបត្តិការក្នុងប្រទេស

ដើម្បីអភិវឌ្ឍស្ថាប័នរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពខ្ពស់ **ន.ធ.ក.** ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងស្ថាប័ននិងដៃគូពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសដោយសកម្ម ចូលរួមក្នុងគ្រប់យន្តការសម្របសម្រួលភាពជាដៃគូនិងកិច្ចព្រមព្រៀងនានា សំដៅអភិវឌ្ឍវិស័យធានារ៉ាប់រងឱ្យកាន់តែមានចីរភាព។ ក្នុងន័យនេះ **ន.ធ.ក.** ត្រូវពង្រឹងភាពជាដៃគូរវាងនិយ័តករធានារ៉ាប់រងកម្ពុជា និងគ្រឹះស្ថានធានារ៉ាប់រង និងសមាគមធានារ៉ាប់រងកម្ពុជា, ជំរុញនិងលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងវិស័យឯកជនដោយសម្របសម្រួលឱ្យសមាគមធានារ៉ាប់រងកម្ពុជាមានតំណាងក្នុងវេទិការាជរដ្ឋាភិបាល និងវិស័យឯកជន, ពង្រឹងកិច្ចសហការជាមួយបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច,

ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.** និងនិយ័តករពាក់ព័ន្ធ, ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីជំរុញប្រតិបត្តិការនៃការផ្តល់សេវាធានារ៉ាប់រង, ពង្រឹងនិងពង្រីកកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្មដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិពាក់ព័ន្ធនឹងសមត្ថកិច្ចរួមរបស់ក្រសួងពាណិជ្ជកម្ម និងនិយ័តករធានារ៉ាប់រងកម្ពុជា, និងរៀបចំនីតិវិធីប្រតិបត្តិ (SOP) របស់និយ័តករធានារ៉ាប់រងកម្ពុជាសម្រាប់ប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**ខ. កិច្ចសហប្រតិបត្តិការអន្តរជាតិ**

បន្ថែមលើកិច្ចសហប្រតិបត្តិការក្នុងប្រទេស និងផ្អែកលើនិន្នាការមួយចំនួននៃសេរីភាវូបនីយកម្មនិងសមាហរណកម្មតំបន់ **ន.ធ.ក.** ត្រូវតែពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិឱ្យបានរឹងមាំនិងជាប្រចាំដោយចូលរួមវេទិកាកិច្ចពិភាក្សា កិច្ចប្រជុំនិងកិច្ចព្រមព្រៀងទ្វេភាគី និងពហុភាគី សំដៅជំរុញការអភិវឌ្ឍវិស័យធានារ៉ាប់រងកម្ពុជា ឱ្យមានសន្ទុះកាន់តែខ្លាំងឡើង។ **ន.ធ.ក.** ត្រូវចូលរួមនិងតាមដានការអនុវត្តសេរីភាវូបនីយកម្មនិងសមាហរណកម្មក្នុងក្របខណ្ឌតំបន់ តាមរយៈកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting) និងកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization), ចូលជាសមាជិកឡើងវិញ ក្នុងក្របខណ្ឌសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS) ដើម្បីចាប់យកកាលានុវត្តភាពចំណេះដឹង និងបទពិសោធន៍ថ្មីៗ សម្រាប់អភិវឌ្ឍស្ថាប័ន និងវិស័យធានារ៉ាប់រង។

## ៦.២. ក្របខណ្ឌបច្ចេកទេស

### ៦.២.១. ការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ

ចំពោះវិធីសាស្រ្តត្រួតពិនិត្យ នៅក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ **ន.ធ.ក.** ត្រូវរៀបចំវិធីសាស្រ្តអនុវត្តច្បាស់លាស់ សម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រង (Analysis Procedure

Manual) និងវិធីសាស្ត្រអនុវត្ត សម្រាប់ត្រួតពិនិត្យ (Examination Procedures and Policy Manual) ដើម្បីប្តូរពីវិធីសាស្ត្រត្រួតពិនិត្យតាមបទប្បញ្ញត្តិកំណត់ (Rule-Based Supervision) ទៅជាវិធីសាស្ត្រត្រួត-ពិនិត្យ តាមកម្រិតហានិភ័យ (Risk-Based Supervision)។

ជាមួយគ្នានេះ **ន.ធ.ក.** ក៏ត្រូវរៀបចំនិងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិប្រុងប្រយ័ត្នចាំបាច់មួយចំនួនដូចជា បទប្បញ្ញត្តិអំពីការកំណត់ដើមទុនអប្បបរមា និងកម្រិតសាធនភាពរបស់ក្រុមហ៊ុនដែលដាក់ឱ្យអនុវត្តនូវវិធីសាស្ត្រគណនាដើមទុន និងកម្រិតសាធនភាពតាមទំហំហានិភ័យកម្រិត ១ (Solvency I or RBC I), ការចុះបញ្ជីក្រុមហ៊ុនសវនកម្មក្នុងវិស័យធានារ៉ាប់រង, ការកំណត់គោលការណ៍វិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង, ការគណនាប្រាក់បម្រុងធានារ៉ាប់រង, និងការធានារ៉ាប់រងបន្តជាដើម។

ក្នុងរយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) **ន.ធ.ក.** នឹងនៅបន្តប្រើប្រាស់ ព្រមទាំងពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមទំហំនៃហានិភ័យរបស់ក្រុមហ៊ុន **(កម្រិត១)**។ បន្ថែមពីនេះ **ន.ធ.ក.** ត្រូវសិក្សាអំពីវិធីសាស្ត្រកំណត់ដើមទុនតាមទំហំហានិភ័យកម្រិត២ (Solvency II or Risk-Based Capital-RBC II) ដើម្បីឆ្លើយតបនឹងទំហំហានិភ័យរបស់ក្រុមហ៊ុន និងត្រូវពិនិត្យឡើងវិញលើបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួន ដើម្បីឆ្លើយតបនឹងការវិវត្តន៍ថ្មីៗក្នុងវិស័យធានារ៉ាប់រង។

### ៦.២.២. ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ

នៅក្នុងរយៈពេល ៣ ឆ្នាំ (២០២៣-២០២៥) **ន.ធ.ក.** ត្រូវពង្រឹងសមត្ថភាពមន្ត្រីជំនាញផ្នែកអភិវឌ្ឍន៍ទីផ្សារក្នុងការតាមដាន និងវាយតម្លៃប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រងដោយបង្កើនការបណ្តុះបណ្តាលជំនាញទាំងក្នុងនិងក្រៅប្រទេស និងបង្កើនចំនួនមន្ត្រីទទួលបន្ទុកដោយមានផែនការច្បាស់លាស់។ រីឯវិធីសាស្ត្រត្រួតពិនិត្យ **ន.ធ.ក.** ត្រូវរៀបចំវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ (Market Conduct Examination Procedure Manual) និងចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីវាយតម្លៃ និងចាត់វិធានការទាន់ពេល ចំពោះអំពើល្មើសនឹងបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការទីផ្សារធានារ៉ាប់រង។

ជាមួយនេះផងដែរ ដើម្បីគាំទ្រដល់ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ **ន.ធ.ក.** ត្រូវរៀបចំបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការទីផ្សារឱ្យបានគ្រប់គ្រាន់ដូចជា សេចក្តីណែនាំស្តីពីគោលការណ៍អប្បបរមានៃកិច្ចសន្យាធានារ៉ាប់រង, ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនធានារ៉ាប់រង, ប្រកាសស្តីពីការចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល និងប្រកាសស្តីពីកិច្ចការពារអ្នកប្រើប្រាស់សេវាធានារ៉ាប់រងជាដើម។ បន្ទាប់មកនៅក្នុងឆ្នាំ២០២៥ **ន.ធ.ក.** នឹងត្រូវពិនិត្យឡើងវិញលើបទប្បញ្ញត្តិដែលមានស្រាប់ពាក់ព័ន្ធនឹងប្រតិបត្តិការទីផ្សារធានារ៉ាប់រងដើម្បីឆ្លើយតបនឹងការវិវត្តថ្មីៗនៃទីផ្សារធានារ៉ាប់រងកម្ពុជា ក៏ដូចជាតំបន់ និងសកល។

### ៦.២.៣. កិច្ចការពារអតិថិជន

នៅក្នុងឆ្នាំ២០២៣-២០២៤ **ន.ធ.ក.** ពង្រឹងតួនាទីរបស់ការិយាល័យផ្សះផ្សាវិវាទធានារ៉ាប់រងឱ្យសកម្មដែលជាយន្តការទីផ្សារដើម្បីផ្សះផ្សា និងដោះស្រាយបណ្តឹងធានារ៉ាប់រង ឱ្យបានទូលំទូលាយដើម្បីបង្កើនជំនឿទុកចិត្តរបស់អតិថិជន ដោយដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ដើម្បីទទួលបណ្តឹងធានារ៉ាប់រងតាមរយៈគេហទំព័ររបស់ **ន.ធ.ក.** ។ ក្នុងឆ្នាំ២០២៥ **ន.ធ.ក.** នឹងបន្តពង្រឹងតួនាទីផ្សះផ្សា និងដោះស្រាយបណ្តឹងធានារ៉ាប់រង និងពង្រីកសេវាទទួលពាក្យបណ្តឹងពីអតិថិជន ឱ្យបានទូលំទូលាយនិងសិក្សារៀបចំបង្កើតវេទិការមជ្ឈត្តករធានារ៉ាប់រងផងដែរ។

### ៦.២.៤. ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង

ការបណ្តុះបណ្តាលវិជ្ជាជីវៈបានដើរតួនាទីយ៉ាងសំខាន់ ចំពោះក្រុមហ៊ុនធានារ៉ាប់រងក៏ដូចជាអតិថិជន និងរួមចំណែកដ៏ខ្លាំងក្លាក្នុងការជំរុញកំណើនទីផ្សារធានារ៉ាប់រង។ ដូច្នេះ ការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យធានារ៉ាប់រង គឺជាផែនការសកម្មភាពដ៏ចាំបាច់ សម្រាប់បម្រើឱ្យទីផ្សារធានារ៉ាប់រង។ **ន.ធ.ក.** ត្រូវសិក្សារៀបចំឱ្យមានទាំង វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង ក៏ដូចជាកម្មវិធីសិក្សាមូលដ្ឋានសម្រាប់ជំនាញធានារ៉ាប់រងក្នុងកម្រិតឧត្តមសិក្សា ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងអប់រំ យុវជននិងកីឡា, សមាគមគ្រឹះស្ថានឧត្តមសិក្សា និងសមាគមធានារ៉ាប់រងកម្ពុជាជាដើម។ លើស

ពីនេះ **ន.ធ.ក.** នឹងសិក្សានិងរៀបចំបង្កើត **"សាលាឬវិទ្យាស្ថានជាតិធានារ៉ាប់រង"** ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈក្នុងវិស័យធានារ៉ាប់រងផ្លូវការផងដែរ ក្នុងឆ្នាំ២០២៥។

ទន្ទឹមនឹងនោះ **ន.ធ.ក.** នឹងរៀបចំកែសម្រួលបទប្បញ្ញត្តិ ស្តីពីការផ្តល់អាជ្ញាបណ្ណ ឬការចុះបញ្ជីអន្តរការីធានារ៉ាប់រង ក្នុងការទទួលស្គាល់លទ្ធផលសិក្សាក្រោមវគ្គបណ្តុះបណ្តាលផ្លូវការ និងជំរុញការរៀបចំបង្កើតសមាគមជើងសាធានារ៉ាប់រងកម្ពុជា ក៏ដូចជាបន្តជំរុញការចូលរួមវគ្គបណ្តុះបណ្តាលធនធានមនុស្សនៅក្នុងវិស័យធានារ៉ាប់រង និងធនធានមនុស្សដែលស្វែងរកការងារ នៅក្នុងវិស័យធានារ៉ាប់រងផងដែរ។

### ៦.២.៥. ការផ្សព្វផ្សាយ និងការអប់រំសាធារណជន

ក្នុងរយៈពេលបីឆ្នាំនេះ ដើម្បីបញ្ជ្រាបការយល់ដឹងរបស់សាធារណជន អំពីសារប្រយោជន៍នៃការធានារ៉ាប់រងឱ្យកាន់តែទូលំទូលាយ **ន.ធ.ក.** ត្រូវរៀបចំសកម្មភាពអប់រំនិងផ្សព្វផ្សាយមួយចំនួនរួមមាន រៀបចំស្ប៉ុតអប់រំ និងផ្សព្វផ្សាយជាប្រចាំតាមទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ, ចូលរួមកម្មវិធីកិច្ចពិភាក្សានិងព្រឹត្តិការណ៍នានាដែលផ្សព្វផ្សាយអំពីការធានារ៉ាប់រង, រៀបចំសិក្ខាសាលាផ្សព្វផ្សាយទូទាំងប្រទេសជាប្រចាំដោយសហការជាមួយសមាគម និងគ្រឹះស្ថានធានារ៉ាប់រង និងសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីផ្សព្វផ្សាយអំពីទីផ្សារការងារនៃវិស័យធានារ៉ាប់រង ដែលកំពុងមានសក្តានុពលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ៦.២.៦. ការធានារ៉ាប់រងជាកាតព្វកិច្ច

**ន.ធ.ក.** ត្រូវអនុវត្តការងារមួយចំនួន នៅក្នុងឆ្នាំ២០២៣-២០២៤ ដើម្បីជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ដែលមានកំណត់ដោយច្បាប់តាំងពីឆ្នាំ២០០០ មកម្ល៉េះរួមមាន រៀបចំអនុក្រឹត្យស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ច ចំពោះយានយន្តគ្រប់ប្រភេទ, បង្កើតនិងដាក់ឱ្យដំណើរការមូលនិធិធានារ៉ាប់រងជនរងគ្រោះដោយសារគ្រោះថ្នាក់ចរាចរណ៍, ពង្រឹងយន្តការក្រុមការងារអន្តរក្រសួងសម្រាប់អនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ដោយកែសម្រួលសមាសភាព និងមានកិច្ចប្រជុំទៀងទាត់, សិក្សានិងផ្តល់យោបល់ជាក្របខណ្ឌគោលនយោបាយ អំពីផលិតផលធានារ៉ាប់រងបន្ថែម ដើម្បីដាក់ជាកាតព្វកិច្ច ក្នុងគោលដៅរួមចំណែកទ្រទ្រង់ដល់ប្រព័ន្ធសន្តិសុខសង្គម។ បន្ថែមពីនេះ **ន.ធ.ក.** នឹងសិក្សា

រៀបចំក្របខណ្ឌការងារចាំបាច់ សម្រាប់ការដាក់ជាកាតព្វកិច្ចនូវផលិតផលធានារ៉ាប់រងអគ្គិភ័យ និង ផលិតផលធានារ៉ាប់រងភារៈទទួលខុសត្រូវសាធារណជន ចំពោះអគារធំៗ។

## ៦.៣. ក្របខណ្ឌបញ្ញត្តិកម្ម

ជាក្របខណ្ឌបញ្ញត្តិកម្មសម្រាប់គាំទ្រដល់ការបំពេញតួនាទីនិងភារកិច្ចរបស់ **ន.ធ.ក.** នឹង ជំរុញការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តថ្មី និងធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិមួយចំនួនក្នុងរយៈពេល ២០២៣-២០២៥ ដូចខាងក្រោម÷

### ការកែសម្រួលបទប្បញ្ញត្តិចាស់

- អនុក្រឹត្យ ស្តីពីការធានារ៉ាប់រង ជំនួសអនុក្រឹត្យឆ្នាំ២០០១
- ប្រកាសអន្តរក្រសួង ស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ច
- ប្រកាស ស្តីពីការផ្តល់អាជ្ញាបណ្ណអាជីវកម្មរបស់គ្រឹះស្ថានធានារ៉ាប់រង
- ប្រកាស ស្តីពីអភិបាលកិច្ចក្រុមហ៊ុនធានារ៉ាប់រង
- ប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង
- ប្រកាស ស្តីពីគោលការណ៍ណែនាំគណនេយ្យសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង
- បទប្បញ្ញត្តិប្រុងប្រយ័ត្នទាក់ទងនឹងការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ
- បទប្បញ្ញត្តិទាក់ទងនឹងក្រុមប្រតិបត្តិទីផ្សារធានារ៉ាប់រង។

### ការរៀបចំបទប្បញ្ញត្តិថ្មី

- អនុក្រឹត្យ ស្តីពីការធានារ៉ាប់រងជាកាតព្វកិច្ចចំពោះយានយន្តគ្រប់ប្រភេទ
- អនុក្រឹត្យ ស្តីពីការធានារ៉ាប់រងខ្នាតតូច
- ប្រកាស ស្តីពីការបង្កើតនិងការគ្រប់គ្រងមូលនិធិអភិវឌ្ឍន៍វិស័យធានារ៉ាប់រង
- ប្រកាសស្តីពីការកំណត់ដើមទុនអប្បបរមានិងកម្រិតសាធនភាពរបស់ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច

- ប្រកាស ស្តីពីវិធាន និងនីតិវិធីនៃការគណនាប្រាក់បម្រុងបច្ចេកទេសធានារ៉ាប់រង
- ប្រកាស ស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង
- ប្រកាស ស្តីពីការធានារ៉ាប់រងបន្ត
- ប្រកាស ស្តីពីការទទួលស្គាល់ក្រុមហ៊ុនផ្តល់សេវនកម្មក្នុងវិស័យធានារ៉ាប់រង
- បទប្បញ្ញត្តិទាក់ទងនឹងសោធននឯកជន
- បទប្បញ្ញត្តិទាក់ទងនឹងប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង
- បទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀត។

## ផ្នែកទី៧÷ យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃ

ដើម្បីធានាបាននូវគុណភាពនិងវឌ្ឍនភាពទីផ្សារធានារ៉ាប់រង “ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥ របស់ **ន.ធ.ក.**” មានគោលដៅសម្រេចឱ្យបាននូវសូចនាករគន្លឹះចំនួនពីរ÷ ១).អត្រាភាគទានធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនឹងត្រូវឈានដល់ប្រមាណ ២% និង ២).ដង់ស៊ីតេធានារ៉ាប់រងប្រមាណ ៤០ដុល្លារអាមេរិក សម្រាប់មនុស្សម្នាក់ៗក្នុងឆ្នាំ២០២៥ ដែលជាចំណោលបង្គោលចរសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវសូចនាករគន្លឹះគោលដៅចុងក្រោយ ដូចបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០។ ក្នុងន័យនេះ យន្តការអនុវត្ត ការត្រួតពិនិត្យ និងការវាយតម្លៃផែនការនេះត្រូវកំណត់ដូចខាងក្រោម÷

### ៧.១. ស្ថាប័នទទួលបន្ទុក

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពខ្ពស់ ក្នុងការអនុវត្តនូវផែនការសកម្មភាពខាងលើនេះទាមទារឱ្យមានផងដែរនូវកិច្ចសហការពីស្ថាប័នពាក់ព័ន្ធ និងការបែងចែកការទទួលខុសត្រូវច្បាស់លាស់ដែលមានដូចខាងក្រោម÷

- **ការអនុវត្ត÷ ន.ធ.ក.** មានតួនាទីជាអ្នកអនុវត្តនូវ **“ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥”** នេះ

- **ការត្រួតពិនិត្យ÷ ន.ធ.ក.** មានតួនាទីជាអ្នកត្រួតពិនិត្យ ដោយមានកិច្ចសហការ និងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋានរបស់ **អ.ស.ហ.** ជាពិសេសអង្គភាពសវនកម្មផ្ទៃក្នុង
- **ការវាយតម្លៃ÷** ក្រុមប្រឹក្សា **អ.ស.ហ.** ជាអ្នកដឹកនាំការងារវាយតម្លៃ និងផ្តល់អនុសាសន៍ដើម្បីកែសម្រួល "**ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥**" របស់ **ន.ធ.ក.**។

## ៧.២. ការត្រួតពិនិត្យ និងការវាយតម្លៃ

នៅក្នុងដំណើរការអនុវត្តការត្រួតពិនិត្យ និងការវាយតម្លៃ "**ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥**" នេះត្រូវរៀបចំឱ្យមាន÷

- ការត្រួតពិនិត្យនិងការវាយតម្លៃជាប្រចាំឆ្នាំ លើសមិទ្ធផលដែលសម្រេចបាន និងបញ្ហាប្រឈមដែលបានជួបប្រទះ លើការអនុវត្ត "**ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥**"
- ភាពបន្ស៊ីគ្នារវាងផែនការថវិការបស់ **ន.ធ.ក.** ជាមួយនឹងសូចនាករនៃសកម្មភាពការងារដើម្បីធានាបាននូវវឌ្ឍនភាពនៃការអនុវត្តសកម្មភាពការងារ ប្រសិទ្ធភាពនៃការត្រួតពិនិត្យ និងការវាយតម្លៃ
- ភាពជាក់លាក់ នៃការកំណត់សូចនាកររបស់សកម្មភាពការងារ និងភាពបត់បែនចំពោះការអនុវត្តយន្តការត្រួតពិនិត្យនិងវាយតម្លៃផែនការសកម្មភាពការងារ ក្នុងការកែសម្រួលសូចនាករទាំងឡាយណាដែលមានលក្ខណៈស្មុគស្មាញ ដើម្បីចៀសវាងសូចនាករគោលដៅអរូបី ដែលមានការលំបាកក្នុងការសម្រេចបាន និងអាចទទួលយកបាននូវសូចនាករថ្មីៗជំនួសវិញ
- ការចូលរួមអនុវត្តផែនការសកម្មភាពការងារ ពីគ្រប់នាយកដ្ឋាន និងការិយាល័យក្រោមឱវាទរបស់ **ន.ធ.ក.** តាមតួនាទីនិងភារកិច្ចរៀងៗខ្លួន
- ការរៀបចំរបាយការណ៍លទ្ធផល នៃការអនុវត្តសកម្មភាពការងារប្រចាំឆ្នាំ ប្រគល់ជូនក្រុមប្រឹក្សា **អ.ស.ហ.** ក្នុងការពិនិត្យ ណែនាំ ផ្តល់អនុសាសន៍ និង/ឬអនុម័តជាយថាហេតុ លើការស្នើសុំកែសម្រួល និងការធ្វើបច្ចុប្បន្នភាពនានា។

## ផ្នែកទី៨៖ សេចក្តីសន្និដ្ឋាន

ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិលនេះ បានដាក់ចេញនូវអភិក្រមដែលផ្តោតលើក្របខណ្ឌចំនួន ៣ ធំៗគឺ ក្របខណ្ឌស្ថាប័ន ក្របខណ្ឌបច្ចេកទេស និងក្របខណ្ឌបញ្ញត្តិកម្ម ដែលនៅក្នុងក្របខណ្ឌនីមួយៗមានសកម្មភាពគោលសំខាន់ៗ និងសកម្មភាពការងារលម្អិតតូចៗ ដែលមានភាពជាក់លាក់ មានភាពជាប់ទាក់ទងគ្នាជាមួយនឹង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ និងផែនការអភិវឌ្ឍន៍ស្ថាប័នរបស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥ និងមានសង្គតិភាពជាមួយនឹងក្របខណ្ឌពេលវេលាផងដែរ។ ដើម្បីសម្រេចបាននូវទិសដៅដែលបានដាក់ចេញ ក្នុងន័យធានាបាននូវភាពធន់ និងឧត្តមភាពប្រកួតប្រជែង ប្រកបដោយចីរភាពនៅក្នុងវិស័យធានារ៉ាប់រង **ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥** មានតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួលការអនុវត្តជាក់ស្តែង នូវសកម្មភាពការងារអាទិភាពដែលបានដាក់ចេញទៅតាមនាយកដ្ឋានជំនាញនីមួយៗ ឱ្យបានរលូនទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពតាមរយៈការវាយតម្លៃឡើងវិញជាប្រចាំឆ្នាំនូវសមិទ្ធផលនិងបញ្ហាប្រឈម ដើម្បីធ្វើការកែសម្រួលនិងតម្រង់ទិសដៅស្របតាមភាពជាក់ស្តែង។

ជាមួយគ្នានេះ ផ្អែកលើសក្តានុពលនិងភាពរឹងមាំនៃទីផ្សារធានារ៉ាប់រងនៅកម្ពុជាបន្ថែម ដោយការតម្រង់ទិសដៅច្បាស់លាស់ តាមរយៈគោលនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០ និងផែនការអភិវឌ្ឍន៍ស្ថាប័ន របស់និយ័តករធានារ៉ាប់រងកម្ពុជា ២០២១-២០២៥ **ន.ធ.ក.** រំពឹងថានឹងសម្រេចបាននូវសូចនាករសំខាន់ៗចំនួនពីរសម្រាប់វាស់វែងការរីកចម្រើននៃវិស័យធានារ៉ាប់រង គឺអត្រាភាគទានក្នុងសេដ្ឋកិច្ចចំនួន ប្រមាណ ២% និងដង់ស៊ីតេធានារ៉ាប់រងប្រមាណ ៤០ ដុល្លារអាមេរិកសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០២៥ ដែលជាចំណោលបង្គោលចរសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ ដើម្បីឈានឆ្ពោះទៅសម្រេចបាននូវសូចនាករគន្លឹះគោលដៅចុងក្រោយដូចបានដាក់ចេញក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យធានារ៉ាប់រងកម្ពុជា ២០២១-២០៣០។

# ផ្នែកទី៩ ៖ តារាងឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១. សមិទ្ធផលសកម្មភាពការងាររបស់ន.ធ.ក.ឆ្នាំ២០២២

| | សកម្មភាព | លទ្ធផលរំពឹងទុកប្រចាំឆ្នាំ | វឌ្ឍនភាព សម្រេចបាន | វឌ្ឍនភាពធៀបនឹងលទ្ធផលរំពឹងទុកប្រចាំឆ្នាំ (%) | ឯកសារអំណះអំណាង | ផ្សេងៗ |
|---|---|---|---|---|---|---|
| **១. ក្របខណ្ឌស្ថាប័ន** | | | | | | |
| **១.១ សមត្ថភាពស្ថាប័ន (Capacity)** | | | | | | |
| | សិក្សានិងរៀបចំសំណើតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋានការិយាល័យ និងមន្ត្រីនៃ **ន.ធ.ក.** តាមភាពចាំបាច់ | ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំការិយាល័យនៃនិយ័តករធានារ៉ាប់រងកម្ពុជា | បានរៀបចំប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំការិយាល័យនៃនិយ័តករធានារ៉ាប់រងកម្ពុជា | ១០០% | ប្រកាសស្តីពីការតែងតាំងថ្នាក់ដឹកនាំការិយាល័យនៃនិយ័តករធានារ៉ាប់រងកម្ពុជា | |
| | រៀបចំបទប្បញ្ញត្តិទទួលស្គាល់មន្ត្រីលក្ខន្តិកៈ | ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ចូលបម្រើការងារនៅ **ន.ធ.ក.** | បានរៀបចំប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ អ. ស. ហ. ចូលបម្រើការងារនៅ **ន.ធ.ក.** | ១០០% | ប្រកាសស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** ចូលបម្រើការងារនៅ **ន.ធ.ក.** | |
| | រៀបចំបែងចែកភារកិច្ចថ្នាក់ដឹកនាំ **ន.ធ.ក.** តាមភាពចាំបាច់ | សេចក្តីសម្រេចស្តីពីការ បែងចែកភារកិច្ចថ្នាក់ដឹកនាំ **ន.ធ.ក.** | បានរៀបចំ និងទទួលបានការអនុម័តលើប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជា | ១០០% | ប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករធានារ៉ាប់រងកម្ពុជា | |

| | | | | | | |
|---|---|---|---|---|---|---|
| | ជ្រើសរើសមន្ត្រី ១០ រូប | លទ្ធផលស្ថាពរនៃការប្រឡងជ្រើសរើសមន្ត្រីត្រូវបានផ្សព្វផ្សាយ | បានជ្រើសរើសមន្ត្រី ១៣រូប ឱ្យចូលបម្រើការងារ | ១០០% | របាយការណ៍ជ្រើសរើសមន្ត្រីលក្ខន្តិកៈ | |
| | រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស | របាយការណ៍លទ្ធផលនៃវគ្គបណ្តុះបណ្តាល | បានរៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស | ១០០% | របាយការណ៍លទ្ធផលនៃវគ្គបណ្តុះបណ្តាល | |
| | រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | របាយការណ៍លទ្ធផលនៃវគ្គបណ្តុះបណ្តាល | បានរៀបចំវគ្គបណ្តុះបណ្តាលសិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស ចំនួន ១៥លើក | ១០០% | របាយការណ៍លទ្ធផលនៃវគ្គបណ្តុះបណ្តាល ចំនួន ១៥ | |
| **១.២. ការតភ្ជាប់ (Connectivity)** | | | | | | |
| | សិក្សានិងរៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | គ្រោង (Outline) នៃឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | បានរៀបចំគ្រោង (Outline) នៃឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | ១០០% | គ្រោង (Outline) នៃឯកសារយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | |
| | សម្របសម្រួលរៀបចំកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សាដោយសហការជាមួយក្រសួងអប់រំ យុវជននិងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា | របាយការណ៍លទ្ធផលនៃកម្មវិធីសិក្សាជំនាញធានារ៉ាប់រងមាននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា | បានរៀបចំកិច្ចប្រជុំជាមួយជាមួយក្រសួងអប់រំ យុវជននិងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា លើកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សា | ១០០% | របាយការណ៍លទ្ធផលនៃកម្មវិធីសិក្សាជំនាញធានារ៉ាប់រងមាននៅក្នុងគ្រឹះស្ថានឧត្តមសិក្សា | |

| | | | | | | |
|---|---|---|---|---|---|---|
| **១.៣. កិច្ចសហប្រតិបត្តិការ (Cooperation)** | | | | | | |
| **១.៣.១. កិច្ចសហប្រតិបត្តិការក្នុងប្រទេស** | | | | | | |
| | រៀបចំបង្កើតភាពជាដៃគូច្បាស់លាស់រវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រងនិងសម្របសម្រួលវិស័យឯកជនធានារ៉ាប់រងឱ្យបានចូលរួមក្នុងវេទិការាជរដ្ឋាភិបាលនិងវិស័យឯកជន | របាយការណ៍កិច្ចពិគ្រោះយោបល់ជាមួយប្រតិបត្តិករលើបញ្ហាប្រឈមដែលកើតមានឡើងក្នុងវិស័យធានា-រ៉ាប់រង | បានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយគ្រឹះស្ថានធានារ៉ាប់រង និងសមាគមធានា-រ៉ាប់រងលើបញ្ហាប្រឈមដែលកើតមានឡើងក្នុងវិស័យធានារ៉ាប់រង | ១០០% | របាយការណ៍កិច្ចពិគ្រោះយោបល់ជាមួយគ្រឹះស្ថានធានារ៉ាប់រងអំពីផលប៉ះពាល់នៃកូវីដ-១៩ លើវិស័យធានារ៉ាប់រង | ផ្លាស់ប្តូរលទ្ធផលរំពឹងទុក |
| | ពង្រឹងនិងពង្រីកកិច្ចសហ-ប្រតិបត្តិការជាមួយនិយ័តករនានាក្រោមឱវាទរបស់ **អ.ស.ហ.** | យន្តការសម្របសម្រួលរវាងនិយ័តករទាំងអស់នៃ **អ.ស.ហ.** ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព | បានបង្កើតយន្តការសម្របសម្រួលរវាងនិយ័តករទាំងអស់នៃ **អ.ស.ហ.** ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព | ១០០% | លិខិតឆ្លើយតប ផ្តល់យោបល់ឬធាតុចូល និងលិខិតពាក់ព័ន្ធផ្សេងៗ | |
| | ពង្រីកកិច្ចសហប្រតិបត្តិការជាមួយធនាគារជាតិនៃកម្ពុជាដើម្បីជំរុញប្រតិបត្តិការផ្តល់សេវាធានារ៉ាប់រងតាមរយៈគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុដែលហៅថា ប៊ែងកា-ស្សូរេន (Bancassurance) | លិខិតបទដ្ឋានគតិយុត្តដែលអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុអាចលក់ផលិតផលធានារ៉ាប់រង ត្រូវបានអនុម័ត | បានផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងដល់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ និងបានអនុញ្ញាតដំណើរការអាជីវកម្មភ្នាក់ងារធានា-រ៉ាប់រងតាមបណ្តាសាខាក្នុងស្រុករបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ | ១០០% | ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង | |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំនីតិវិធីប្រតិបត្តិ (SOP) សម្រាប់ការប្រឆាំងការសម្អាតប្រាក់, ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យរបស់ **ន.ធ.ក.** | ស្តង់ដារប្រតិបត្តិ (SOP) សម្រាប់អនុវត្តការស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៅក្នុងវិស័យធានារ៉ាប់រង ត្រូវរៀបចំសម្រាប់អនុវត្ត | ស្តង់ដារប្រតិបត្តិ (SOP) សម្រាប់អនុវត្តការស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៅក្នុងវិស័យធានារ៉ាប់រង ត្រូវរៀបចំសម្រាប់អនុវត្ត | ១០០% | ស្តង់ដារប្រតិបត្តិ (SOP) សម្រាប់អនុវត្តការស៊ើបអង្កេតបទល្មើសហិរញ្ញវត្ថុពាក់ព័ន្ធការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញ-ប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៅក្នុងវិស័យធានារ៉ាប់រង | |
| | រៀបចំក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិង **ន.ធ.ក.** | សេចក្តីសម្រេចបង្កើតក្រុមការងារចំរុះត្រូវបានចុះហត្ថលេខាជាផ្លូវការ | បានរៀបចំសេចក្តីសម្រេចបង្កើតក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងសមត្ថកិច្ចរបស់ក្រសួងពាណិជ្ជកម្មនិង **ន.ធ.ក.** | ១០០% | សេចក្តីសម្រេចបង្កើតក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តបទប្បញ្ញត្តិទាក់ទងនឹងសមត្ថ-កិច្ចរបស់ក្រសួងពាណិជ្ជកម្មនិង **ន.ធ.ក.** | |
| | សិក្សាលើនីតិវិធីចូលជាសមាជិកឡើងវិញក្នុងសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS) | និយ័តករធានារ៉ាប់រងកម្ពុជាត្រូវបានបញ្ចូលជាសមាជិកនៃ សមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (IAIS) | បានរៀបចំរបាយការណ៍សិក្សាអំពីនីតិវិធីនៃការចូលជាសមាជិកសមាគមនិយ័តករធានា-រ៉ាប់រងអន្តរជាតិ (IAIS) និងបានស្នើសុំចូលជាសមាជិក | ១០០% | របាយការណ៍សិក្សាអំពីនីតិវិធីនៃការចូលជាសមាជិកសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (IAIS) | |
| **១.៣.២. កិច្ចសហប្រតិបត្តិការអន្តរជាតិ** | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM) | របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ AIRM | បានចូលរួមនិងតាមដានកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (AIRM) | ១០០% | របាយការណ៍លទ្ធផលនៃកិច្ចប្រជុំ AIRM | |
| | ចូលរួមនិងតាមដានកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) និងកិច្ចប្រជុំនានាក្នុងក្របខណ្ឌតំបន់និងសកលលោក | របាយការណ៍កិច្ចប្រជុំតំបន់និងអន្តរជាតិដើម្បីតាមដានការធ្វើសេរីភាវូបនីយកម្មវិស័យធានារ៉ាប់រងក្នុងតំបន់ និងអន្តរជាតិ | បានចូលរួមកិច្ចប្រជុំតំបន់និងអន្តរជាតិដើម្បីតាមដានការធ្វើសេរីភាវូបនីយកម្មវិស័យធានារ៉ាប់រងក្នុងតំបន់ និងអន្តរជាតិ | ១០០% | របាយការណ៍កិច្ចប្រជុំតំបន់និងអន្តរជាតិដើម្បីតាមដានការធ្វើសេរីភាវូបនីយកម្មវិស័យធានារ៉ាប់រងក្នុងតំបន់និងអន្តរជាតិ | |
| **២. ក្របខណ្ឌបច្ចេកទេស** | | | | | | |
| **២.១. ការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ** | | | | | | |
| | រៀបចំនិងអនុវត្តវិធីសាស្ត្រអនុវត្ត (SOP) សម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រង (Analysis Procedures Manual) និង | ចងក្រងវិធីសាស្ត្រអនុវត្តន៍សម្រាប់ការវិភាគហិរញ្ញវត្ថុ (នីតិវិធីប្រតិបត្តិសម្រាប់ត្រួតពិនិត្យលើឯកសារ) និងវិធីសាស្ត្រអនុវត្តន៍សម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង | -ចងក្រងវិធីសាស្ត្រអនុវត្តន៍សម្រាប់ការវិភាគហិរញ្ញវត្ថុ (នីតិវិធីប្រតិបត្តិសម្រាប់ត្រួតពិនិត្យលើឯកសារ) និងវិធីសាស្ត្រអនុវត្តន៍សម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង (នីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង) | ១០០% | -នីតិវិធីប្រតិបត្តិសម្រាប់ត្រួតពិនិត្យលើឯកសារ និងនីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង | ប្តូរឈ្មោះនីតិវិធីប្រតិបត្តិ |

| | | | | | | |
|---|---|---|---|---|---|---|
| | វិធីសាស្ត្រអនុវត្ត សម្រាប់ត្រួតពិនិត្យ (Examination Procedures and Policy Manual) | (នីតិវិធីប្រតិបត្តិសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង) | -ចងក្រងនីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | | -នីតិវិធីប្រតិបត្តិស្តង់ដា សម្រាប់ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម | |
| | ត្រួតពិនិត្យដល់ទីកន្លែងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង | -របាយការណ៍ចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតតាមបណ្ដាសាខាចំនួន៥<br>-របាយការណ៍ចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងទូទៅតាមបណ្ដាសាខាចំនួន ៦ | -បានចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតតាមបណ្ដាសាខាចំនួន៥<br>-បានចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងទូទៅតាមបណ្ដាសាខាចំនួន ៦ | ១០០% | -របាយការណ៍ចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតតាមបណ្ដាសាខាចំនួន៥<br>-របាយការណ៍ចុះត្រួតពិនិត្យក្រុមហ៊ុនធានារ៉ាប់រងទូទៅតាមបណ្ដាសាខាចំនួន ៦ | |
| **២.២. ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ** | | | | | | |
| | រៀបចំនិងដាក់ឱ្យអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ (Market Conduct Examination Procedure Manual) | វិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ (Market Conduct Examination Procedure Manual) ត្រូវបានដាក់ឱ្យអនុវត្ត | វិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ (Market Conduct Examination Procedure Manual) ត្រូវបានដាក់ឱ្យអនុវត្ត | ១០០% | នីតិវិធីប្រតិបត្តិសម្រាប់ត្រួតពិនិត្យប្រតិបត្តិការទីផ្សារ | |
| | ត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រងចំនួន៥ | របាយការណ៍ត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានា-រ៉ាប់រងចំនួន៥ | បានចុះត្រួតពិនិត្យប្រតិបត្តិការទីផ្សារលើក្រុមហ៊ុនធានារ៉ាប់រងដល់ទីកន្លែងចំនួន៥ | ១០០% | របាយការណ៍ត្រួតពិនិត្យប្រតិបត្តិការទីផ្សារធានារ៉ាប់រងចំនួន៥ | |
| **២.៣. កិច្ចការពារអតិថិជន** | | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំនិងដាក់ឱ្យប្រើប្រាស់នូវយន្តការទទួលពាក្យបណ្តឹងតាមអនឡាញ | ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាម គេហទំព័ររបស់ **ន.ធ.ក.** ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់ | បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាមគេហទំព័ររបស់ **ន.ធ.ក.** ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់ | ១០០% | ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាម គេហទំព័ររបស់ **ន.ធ.ក.** | |
| **២.៤.ការបណ្តុះបណ្តាលវិជ្ជាជីវៈធានារ៉ាប់រង** | | | | | | |
| | ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលនិងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង | របាយការណ៍លទ្ធផលអំពីការចុះត្រួតពិនិត្យលើការបណ្តុះបណ្តាលនិងការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ចំនួន៣ | បានត្រួតពិនិត្យការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងដល់ទីកន្លែងចំនួន ៣ដង | ១០០% | ការប្រឡងបញ្ចប់វគ្គបណ្តុះបណ្តាលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងចំនួន ៣ | |
| | ជំរុញការរៀបចំបង្កើតសមាគមជើងសាធានារ៉ាប់រងកម្ពុជា | សមាគមជើងសាធានារ៉ាប់រងកម្ពុជា ត្រូវបានបង្កើតជាផ្លូវការ | បានជំរុញការបង្កើតជាផ្លូវការនូវសមាគមជើងសាធានារ៉ាប់រងកម្ពុជា | ១០០% | សមាគមជើងសាធានារ៉ាប់រងកម្ពុជា ត្រូវបានបង្កើតជាផ្លូវការ | |
| **២.៥. ការផ្សព្វផ្សាយនិងការអប់រំសាធារណជន** | | | | | | |
| | រៀបចំផលិតស្ប៉តអប់រំនិងផ្សព្វផ្សាយជាប្រចាំតាមទូរទស្សន៍ និងប្រព័ន្ធបណ្តាញសង្គម | វីដេអូស្ប៉តអប់រំស្តីពីអត្ថប្រយោជន៍នៃការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តឬតតិយជនត្រូវបានរៀបចំនិងផ្សព្វផ្សាយតាមកញ្ចក់ទូរទស្សន៍គេហទំព័រនិងបណ្តាញសង្គមរបស់ **ន.ធ.ក.** | បានរៀបចំផលិតស្ប៉តអប់រំនិងផ្សព្វផ្សាយតាមបណ្តាញសង្គមរបស់ ន.ក.ធ. | ១០០% | វីដេអូស្ប៉តអប់រំស្តីពីអត្ថប្រយោជន៍នៃការធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្តឬតតិយជនត្រូវបានរៀបចំនិងផ្សព្វផ្សាយ តាមកញ្ចក់ទូរទស្សន៍ គេហទំព័រ និងបណ្តាញសង្គមរបស់ **ន.ធ.ក.** | |
| | ចូលរួមកម្មវិធីកិច្ចពិភាក្សា ឬព្រឹត្តិការណ៍នានាដែលផ្សព្វផ្សាយអំពីការធានារ៉ាប់រង | របាយការណ៍អំពីការចូលរួមផ្តល់បាឋកថាអំពីវិស័យធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនិងទីផ្សារការងារ ជូននិស្សិតតាមសកលវិទ្យាល័យចំនួន ១០ | បានរៀបចំបាឋកថាអំពីវិស័យធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនិងទីផ្សារការងារ ជូននិស្សិតតាមសកលវិទ្យាល័យចំនួន ១០ | ១០០% | ឯកសារពាក់ព័ន្ធការផ្តល់បាឋកថាអំពីវិស័យធានារ៉ាប់រងក្នុងសេដ្ឋកិច្ចនិងទីផ្សារការងារ ជូននិស្សិតតាមសកលវិទ្យាល័យ | |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការធានារ៉ាប់រងជាកាតព្វកិច្ចតាមបណ្តាខេត្ត | របាយការណ៍លទ្ធផលសិក្ខាសាលាផ្សព្វផ្សាយអំពីការធានារ៉ាប់រងជាកាតព្វកិច្ចតាមបណ្តាខេត្តចំនួន ៤ | បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីការធានារ៉ាប់រងជាកាតព្វកិច្ចតាមបណ្តាខេត្តចំនួន ៤÷<br>- ខេត្តព្រះសីហនុ<br>- ខេត្តកំពត<br>- ខេត្តកំពង់ស្ពឺ<br>- ខេត្តបាត់ដំបង | ១០០% | របាយការណ៍លទ្ធផលសិក្ខាសាលាផ្សព្វផ្សាយអំពីការធានារ៉ាប់រងជាកាតព្វកិច្ចតាមបណ្តាខេត្តចំនួន ៤ | |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធានារ៉ាប់រង និងសោធនឯកជន | របាយការណ៍លទ្ធផលនៃការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធានារ៉ាប់រងនិងសោធនឯកជន ចំនួន ៦ លើក | បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធានារ៉ាប់រងនិងសោធនឯកជន ចំនួន ៩ លើក | ១០០% | របាយការណ៍លទ្ធផលនៃការផ្សព្វផ្សាយអំពីលិខិតបទដ្ឋានគតិ-យុត្តពាក់ព័ន្ធនឹងការធានារ៉ាប់រងនិងសោធនឯកជន ចំនួន ៩លើក | |
| | ជំរុញការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការធានារ៉ាប់រងក្នុងក្របខណ្ឌទូទាំងប្រទេស | របាយការណ៍នៃកិច្ចប្រជុំផ្សព្វផ្សាយអំពីការអនុវត្តកាតព្វកិច្ចធានារ៉ាប់រងយានយន្តឆ្លងកាត់ព្រំដែន | បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ និងពិភាក្សាស្តីពី ការដាក់ឱ្យដំណើរការធានារ៉ាប់រងយានយន្តឆ្លងកាត់ព្រំដែន | ១០០% | របាយការណ៍លទ្ធផលនៃកិច្ចប្រជុំផ្សព្វផ្សាយ និងពិភាក្សាស្តីពី ការដាក់ឱ្យដំណើរការធានារ៉ាប់រងយានយន្តឆ្លងកាត់ព្រំដែន | |
| **២.៦ ការធានារ៉ាប់រងជាកាតព្វកិច្ច** | | | | | | |
| | រៀបចំឯកសារស្តីពីប្រព័ន្ធគ្រប់គ្រងការធានារ៉ាប់រងជាកាតព្វកិច្ចចំពោះយានយន្តគ្រប់ប្រភេទ | ឯកសារស្តីពីប្រព័ន្ធគ្រប់គ្រងការធានារ៉ាប់រងជាកាតព្វកិច្ចចំពោះយានយន្តគ្រប់ប្រភេទ ត្រូវបានអនុម័ត | បានសិក្សាដើម្បីរៀបចំឯកសារស្តីពីប្រព័ន្ធគ្រប់គ្រងការធានារ៉ាប់រងជាកាតព្វកិច្ចចំពោះយានយន្តគ្រប់ប្រភេទ | ៩០% | ឯកសារស្តីពីប្រព័ន្ធគ្រប់គ្រងការធានារ៉ាប់រងជាកាតព្វកិច្ចចំពោះយានយន្តគ្រប់ប្រភេទ ទទួលបានការឯកភាពត្រឹមកម្រិតអគ្គនាយកនៃ **ន.ធ.ក.** | |

| | | | | | | |
|---|---|---|---|---|---|---|
| | ធ្វើបច្ចុប្បន្នភាពសមាសភាពក្រុមការងារអន្តរក្រសួងសម្រាប់អនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច | ប្រកាសថ្មីស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្ត "ប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង" ត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្ត | បានរៀបចំប្រកាសថ្មីស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្ត "ប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង" ត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្ត | ១០០% | ប្រកាសស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីអនុវត្ត "ប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រង" ត្រូវបានចុះហត្ថលេខាដាក់ឱ្យអនុវត្ត | |
| **៣. ក្របខណ្ឌបញ្ញត្តិកម្ម** | | | | | | |
| | រៀបចំនិងដាក់ឱ្យប្រើប្រាស់នូវយន្តការទទួលពាក្យបណ្តឹងតាមអនឡាញ | ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាម គេហទំព័ររបស់ ន.ធ.ក. ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់ | បានរៀបចំ និងដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាមគេហទំព័ររបស់ **ន.ធ.ក.** ត្រូវបានរៀបចំនិងដាក់ឱ្យប្រើប្រាស់ | ១០០% | ប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ទទួលពាក្យបណ្តឹងតាម គេហទំព័ររបស់ **ន.ធ.ក.** | |
| | រៀបចំប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តកម្ម | ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តកម្ម ត្រូវបានអនុម័តដាក់ឱ្យប្រើប្រាស់ | បានរៀបចំ និងទទួលបានការអនុម័តលើប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តកម្ម | ១០០% | ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការចុះឈ្មោះក្នុងបញ្ជីបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តកម្ម | កែសម្រួលឈ្មោះប្រកាស |
| | រៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច | សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូចត្រូវបានរៀបចំកម្រិតនាយកដ្ឋាន | បានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច កម្រិតនិយ័តករ | ១០០% | សេចក្តីព្រាងអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច | |
| | រៀបចំធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង | ប្រកាសថ្មីស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងត្រូវបានអនុម័ត | បានរៀបចំធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង | ១០០% | រៀបចំធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រង | កែសម្រួលឈ្មោះប្រកាស |

| | | | | | | |
|---|---|---|---|---|---|---|
| | រៀបចំធ្វើបច្ចុប្បន្នភាពប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង | ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានា-រ៉ាប់រងត្រូវបានអនុម័ត | បានរៀបចំ និងទទួលបានការអនុម័តលើប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង | ១០០% | ប្រកាសស្តីពីលក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង | កែសម្រួលឈ្មោះប្រកាស |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | ការរៀបចំផ្សព្វផ្សាយអំពីប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការកំណត់ កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | ១០០% | សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | |
| | រៀបចំប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ភ្នាក់ងារធានារ៉ាប់រង | ប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈរបស់ភ្នាក់ងារធានារ៉ាប់រង ត្រូវបានអនុម័តដាក់ឱ្យអនុវត្ត | បានរៀបចំកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងត្រឹមកម្រិតនិយ័តករធានារ៉ាប់រងកម្ពុជា ជាមួយនឹងសមាគមធានារ៉ាប់រងកម្ពុជា | ៧៥% | សេចក្តីព្រាងប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង | |
| | រៀបចំគោលការណ៍ណែនាំស្តីពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង | គោលការណ៍ណែនាំស្តីពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង ត្រូវបានអនុម័តដាក់ឱ្យអនុវត្ត | បានរៀបចំកិច្ចពិគ្រោះយោបល់លើសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការទទួល និងដោះស្រាយសំណងធានារ៉ាប់រង | ១០០% | គោលការណ៍ណែនាំស្តីពីការទទួលនិងដោះស្រាយសំណងធានារ៉ាប់រង | ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការទទួលនិងដោះស្រាយសំណងធានារ៉ាប់រង ត្រូវបានផ្លាស់ប្តូរពីប្រកាសទៅជាគោលការណ៍ណែនាំវិញ |
| | រៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីបទប្បញ្ញត្តិប្រុងប្រយ័ត្ន | -របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីបទប្បញ្ញត្តិប្រុងប្រយ័ត្ន | បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីបទប្បញ្ញត្តិប្រុងប្រយ័ត្នចំនួន ៣លើក | ១០០% | -របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពីការ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | -របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពីការកំណត់អំពីនីតិវិធី និងវិធាននៃការគណនាប្រាក់បម្រុងធានារ៉ាប់រង<br>-របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង<br>-របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | | | កំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង<br>-របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពីការកំណត់អំពីនីតិវិធី និងវិធាននៃការគណនាប្រាក់បម្រុងធានារ៉ាប់រង<br>-របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពីការអនុញ្ញាតលើការវិនិយោគសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង<br>-របាយការណ៍សិក្ខាសាលាផ្សព្វផ្សាយប្រកាសស្តីពីការកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង | |

## ឧបសម្ព័ន្ធ២. ផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៣-២០២៥

| ល.រ. | សកម្មភាព | ក្របខណ្ឌពេលវេលា | | | នាយកដ្ឋានទទួលបន្ទុក |
|---|---|---|---|---|---|
| | | ២០២៣ | ២០២៤ | ២០២៥ | |
| **១. ក្របខណ្ឌស្ថាប័ន** | | | | | |
| **១.១ សមត្ថភាពស្ថាប័ន (Capacity)** | | | | | |
| **១.១.១** | **រចនាសម្ព័ន្ធស្ថាប័ន** | | សិក្សាវិភាគមុខងារស្ថាប័ន **ន ធ ក.** ផ្អែកលើភាពចាំបាច់ | | **នាយកដ្ឋានកិច្ចការទូទៅ** |
| **១.១.២.** | **អភិបាលកិច្ច** | រៀបចំតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន និងការិយាល័យ នៃ **ន.ធ.ក.** តាមភាពចាំបាច់ | រៀបចំតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន និងការិយាល័យ នៃ **ន.ធ.ក.** តាមភាពចាំបាច់ | រៀបចំតែងតាំងថ្នាក់ដឹកនាំនាយកដ្ឋាន និងការិយាល័យ នៃ **ន.ធ.ក.** តាមភាពចាំបាច់ | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំការទទួលស្គាល់មន្ត្រីលក្ខន្តិកៈ | រៀបចំការទទួលស្គាល់មន្ត្រីលក្ខន្តិកៈ | រៀបចំការទទួលស្គាល់មន្ត្រីលក្ខន្តិកៈ | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំវាយតម្លៃសមិទ្ធកម្មការងាររបស់មន្ត្រី និងថ្នាក់ដឹកនាំ **ន.ធ.ក.** ដើម្បីផ្តល់ការលើកទឹកចិត្ត | រៀបចំវាយតម្លៃសមិទ្ធកម្មការងាររបស់មន្ត្រីនិងថ្នាក់ដឹកនាំ **ន.ធ.ក.** ដើម្បីផ្តល់ការលើកទឹកចិត្ត | រៀបចំវាយតម្លៃសមិទ្ធកម្មការងាររបស់មន្ត្រី និងថ្នាក់ដឹកនាំ **ន.ធ.ក.** ដើម្បីផ្តល់ការលើកទឹកចិត្ត | **នាយកដ្ឋានកិច្ចការទូទៅ** |
| **១.១.៣.** | **ធនធានមនុស្ស** | ជ្រើសរើសមន្ត្រី ១៤ រូប | ជ្រើសរើសមន្ត្រី ២០រូប | ជ្រើសរើសមន្ត្រី ២០រូប | **នាយកដ្ឋានកិច្ចការទូទៅ** |

| | | | | | |
|---|---|---|---|---|---|
| | | រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស | រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស | រៀបចំវគ្គបណ្តុះបណ្តាលជំនាញមូលដ្ឋានសម្រាប់មន្ត្រីថ្មីដែលទើបជ្រើសរើស | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | រៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សាសម្រាប់ថ្នាក់ដឹកនាំនិងមន្ត្រី **ន.ធ.ក.** គ្រប់លំដាប់ថ្នាក់ ទាំងក្នុងនិងក្រៅប្រទេស | **នាយកដ្ឋានកិច្ចការទូទៅ** |
| **១.១.៤.** | **បរិស្ថាននិងលក្ខខណ្ឌការងារ** | សាងសង់អគាររដ្ឋបាលថ្មី | សាងសង់អគាររដ្ឋបាលថ្មី | សាងសង់អគាររដ្ឋបាលថ្មី | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងរដ្ឋបាល (Administration Information System-AIS) ដំណាក់កាលទី២ | | | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យក្រុមហ៊ុន (Company Profile Management Information System-CPMIS) ដំណាក់កាលទី២ | | | **នាយកដ្ឋានកិច្ចការទូទៅ** |
| | | រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មីដូចជា កុំព្យូទ័រ បណ្តាញ | រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មីដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ីនធឺណិត តុ និងទូ ជាដើម | រៀបចំបំពាក់ឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងសម្ភារៈការិយាល័យសម្រាប់បំពេញការងារដល់មន្ត្រីថ្មីដូចជា កុំព្យូទ័រ បណ្តាញតភ្ជាប់ បណ្តាញអ៊ីនធឺណិត តុ និងទូ ជាដើម | **នាយកដ្ឋានកិច្ចការទូទៅ** |

| | | | | | |
|---|---|---|---|---|---|
| | | តភ្ជាប់ បណ្តាញអ៊ីនធឺណិត តុ និងទូ ជាដើម | | | |
| **១.២. ការតភ្ជាប់ (Connectivity)** | | | | | |
| **១.២.១.** | **ការតភ្ជាប់ផ្នែករឹង** | | ជំរុញការបញ្ចូលកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សាដោយសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា | សិក្សា និងវាយតម្លៃកម្មវិធីសិក្សាជំនាញធានារ៉ាប់រងកម្រិតឧត្តមសិក្សាដោយសហការជាមួយក្រសួង អប់រំ យុវជន និងកីឡា និងគ្រឹះស្ថានឧត្តមសិក្សា | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |
| | | សិក្សាសមិទ្ធិលទ្ធភាពអំពីការបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង | រៀបចំបង្កើតសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង | ដាក់ឱ្យដំណើរការសាលា/វិទ្យាស្ថានជាតិធានារ៉ាប់រង | **នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ** |
| **១.២.២.** | **ការតភ្ជាប់ផ្នែកទន់** | រៀបចំប្រព័ន្ធបច្ចេកវិទ្យា ចុះបញ្ជីអន្តរការីធានារ៉ាប់រង (Insurance Agent Registration Information System-IARS) ដំណាក់កាលទី២ | | | **នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណនិងកិច្ចការគតិយុត្ត** |
| | | | សិក្សា និងរៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច (MTPL Data Management System) | សិក្សា និងរៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងទិន្នន័យការធានារ៉ាប់រងយានយន្តជាកាតព្វកិច្ច (MTPL Data Management System) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |

| | | | | | |
|---|---|---|---|---|---|
| | | រៀបចំប្រព័ន្ធប្រមូល និងគ្រប់គ្រងទិន្នន័យទីផ្សារធានារ៉ាប់រង (Insurance Data Collection and Management Information System-IDCMIS) ដំណាក់កាលទី២ | សិក្សារៀបចំប្រព័ន្ធ Supervisory Information System | សិក្សារៀបចំប្រព័ន្ធ Supervisory Information System | **នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ** |
| | | សិក្សាប្រមូលធាតុចូលដើម្បីរៀបចំប្រព័ន្ធបច្ចេកវិទ្យាសម្រាប់វិភាគនិងផ្តល់សញ្ញាមុន (Early Warning System) | | | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | រៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | រៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | បញ្ចប់ការរៀបចំក្របខណ្ឌយុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចេកវិទ្យាធានារ៉ាប់រង (InsurTech) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| | | សិក្សាសមិទ្ធិលទ្ធភាព ក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងវិស័យធានារ៉ាប់រង | បញ្ចប់ការសិក្សាសមិទ្ធិលទ្ធភាពក្នុងការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាធានារ៉ាប់រង ក្នុងទីផ្សារធានារ៉ាប់រង | | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| | | ពង្រឹងភាពជាដៃគូរវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រង | បន្តពង្រឹងភាពជាដៃគូ រវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រង | បន្តពង្រឹងភាពជាដៃគូ រវាង **ន.ធ.ក.** និងប្រតិបត្តិករធានារ៉ាប់រង | **នាយកដ្ឋានកិច្ចការទូទៅ** |

| | | | | | |
|---|---|---|---|---|---|
| **១.៣. កិច្ចសហប្រតិបត្តិការ (Cooperation)** | | | | | |
| **១.៣.១.** | **កិច្ចសហប្រតិបត្តិការក្នុងប្រទេស** | ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ | បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ | បន្តពង្រឹងកិច្ចសហប្រតិបត្តិការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធ | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |
| | | ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គភាពនៃ **អ.ស.ហ.** | បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គភាពនៃ **អ.ស.ហ.** | បន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយអង្គភាពនៃ **អ.ស.ហ.** | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |
| | | បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | បន្តពង្រឹងការចូលរួមអនុវត្តផែនការសកម្មភាពទាក់ទងនឹងការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទាន ភេរវកម្មនិងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |
| | | ចូលរួមយ៉ាងសកម្មក្នុងក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងសមត្ថកិច្ចរួម របស់ក្រសួងពាណិជ្ជកម្មនិង **ន.ធ.ក.** | ចូលរួមយ៉ាងសកម្មក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងសមត្ថកិច្ចរួមរបស់ក្រសួងពាណិជ្ជ-កម្មនិង **ន.ធ.ក.** | ចូលរួមយ៉ាងសកម្មក្រុមការងារចំរុះដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុលិខិតបទដ្ឋានគតិយុត្តទាក់ទងនឹងសមត្ថកិច្ចរួមរបស់ក្រសួងពាណិជ្ជកម្មនិង **ន.ធ.ក.** | **នាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណនិងកិច្ចការគតិយុត្ត** |

| | | | | | |
|---|---|---|---|---|---|
| | | សិក្សាលើនីតិវិធីនិងចូលជាសមាជិកភាពឡើងវិញ ក្នុងសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS) | ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS) | ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំនៃសមាគមនិយ័តករធានារ៉ាប់រងអន្តរជាតិ (International Association of Insurance Supervisors-IAIS) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| **១.៣.២.** | **កិច្ចសហប្រតិបត្តិការអន្តរជាតិ** | ចូលរួមកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM) | ចូលរួមកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM) | រៀបចំកិច្ចប្រជុំនិយ័តករធានារ៉ាប់រងអាស៊ាន (ASEAN Insurance Regulators Meeting-AIRM) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| | | ចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវា-ហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) | ចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) | ចូលរួមកិច្ចប្រជុំក្រុមការងារសម្របសម្រួលអាស៊ាន សម្រាប់សេរីភាវូបនីយកម្មសេវា-ហិរញ្ញវត្ថុ (Working Committee on Financial Services Liberalization) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |
| | | ចូលរួមកិច្ចប្រជុំឆ្លងកាត់ព្រំដែន (Cross border) | ចូលរួមកិច្ចប្រជុំឆ្លងកាត់ព្រំដែន (Cross border) | ចូលរួមកិច្ចប្រជុំឆ្លងកាត់ព្រំដែន (Cross border) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហ-ប្រតិបត្តិការ** |

| | | | | | |
|---|---|---|---|---|---|
| | | ចូលរួមកិច្ចប្រជុំអនុក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុ សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា | ចូលរួមកិច្ចប្រជុំអនុក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុ សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា | ចូលរួមកិច្ចប្រជុំអនុក្រុមការងារផ្នែកសេវាហិរញ្ញវត្ថុ សម្រាប់កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-កាណាដា | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| | | ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលឆ្លងវិស័យអាស៊ានស្តីពីការផ្តល់ហិរញ្ញប្បទាន និងធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (ACSCC-DRFI) | ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលឆ្លងវិស័យអាស៊ានស្តីពីការផ្តល់ហិរញ្ញប្បទាន និងធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (ACSCC-DRFI) | ចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលឆ្លងវិស័យអាស៊ានស្តីពីការផ្តល់ហិរញ្ញប្បទាន និងធានារ៉ាប់រងហានិភ័យគ្រោះមហន្តរាយ (ACSCC-DRFI) | **នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ** |
| **២. ក្របខណ្ឌបច្ចេកទេស** | | | | | |
| **២.១.** | **ការគ្រប់គ្រងនិងត្រួតពិនិត្យហិរញ្ញវត្ថុ** | បណ្តុះបណ្តាលមន្ត្រីជំនាញអំពីការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រងនិងវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យ | បណ្តុះបណ្តាលមន្ត្រីជំនាញអំពីការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រងនិងវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យ | បណ្តុះបណ្តាលមន្ត្រីជំនាញអំពីការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់វិភាគស្ថានភាពហិរញ្ញវត្ថុក្រុមហ៊ុនធានារ៉ាប់រងនិងវិធីសាស្ត្រអនុវត្តសម្រាប់ត្រួតពិនិត្យ | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | ពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមទំហំនៃហានិភ័យរបស់ក្រុមហ៊ុន (កម្រិត១) (Solvency I or Risked-Based Capital-RBC I) | ពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមទំហំនៃហានិភ័យរបស់ក្រុមហ៊ុន (កម្រិត១) (Solvency I or Risked-Based Capital-RBC I) | ពង្រឹងការអនុវត្តវិធីសាស្ត្រត្រួតពិនិត្យតាមទំហំនៃហានិភ័យរបស់ក្រុមហ៊ុន (កម្រិត១) (Solvency I or Risked-Based Capital-RBC I) | **នាយកដ្ឋានត្រួតពិនិត្យ** |

| | | | | | |
|---|---|---|---|---|---|
| | | | សិក្សាអំពីវិធីសាស្ត្រកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង តាមទិហំហានិភ័យកម្រិត២ (Solvency II or Risk-Based Capital- RBC II ) | បន្តសិក្សាអំពីវិធីសាស្ត្រកំណត់កម្រិតសាធនភាពសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង តាមទំហំហានិភ័យកម្រិត២ (Solvency II or Risk-Based Capital- RBC II ) | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | ត្រួតពិនិត្យដល់ទីកន្លែងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង | ត្រួតពិនិត្យដល់ទីកន្លែងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង | ត្រួតពិនិត្យដល់ទីកន្លែងលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនធានារ៉ាប់រង | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | រៀបចំទម្រង់របាយការណ៍ប្រចាំគ្រាសម្រាប់គ្រឹះស្ថានធានារ៉ាប់រង | | | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | បណ្តុះបណ្តាលគ្រឹះស្ថានធានារ៉ាប់រងអំពីទម្រង់របាយការណ៍ប្រចាំគ្រា | បណ្តុះបណ្តាលគ្រឹះស្ថានធានារ៉ាប់រងអំពីទម្រង់របាយការណ៍ប្រចាំគ្រា | បណ្តុះបណ្តាលគ្រឹះស្ថានធានារ៉ាប់រងអំពីទម្រង់របាយការណ៍ប្រចាំគ្រា | **នាយកដ្ឋានត្រួតពិនិត្យ** |
| | | ផ្សព្វផ្សាយបទបញ្ញត្តិប្រុងប្រយ័ត្ន | ផ្សព្វផ្សាយបទបញ្ញត្តិប្រុងប្រយ័ត្ន | ផ្សព្វផ្សាយបទបញ្ញត្តិប្រុងប្រយ័ត្ន | **នាយកដ្ឋានត្រួតពិនិត្យ** |
| **២.២.** | **ការគ្រប់គ្រងនិងត្រួតពិនិត្យប្រតិបត្តិការទីផ្សារ** | ពង្រឹងការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់ការចុះត្រួតពិនិត្យប្រតិបត្តិការទីផ្សារធានារ៉ាប់រង | ពង្រឹងការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់ការចុះត្រួតពិនិត្យប្រតិបត្តិការទីផ្សារធានារ៉ាប់រង | ពង្រឹងការអនុវត្តវិធីសាស្ត្រអនុវត្តសម្រាប់ការចុះត្រួតពិនិត្យប្រតិបត្តិការទីផ្សារធានារ៉ាប់រង | **នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ** |
| | | ត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រង | ត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រង | ត្រួតពិនិត្យដល់ទីកន្លែងលើប្រតិបត្តិការទីផ្សាររបស់ក្រុមហ៊ុនធានារ៉ាប់រង | **នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ** |
